សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# តួនាទីមេធាវីក្នុងនីតិវិធីបណ្ដឹងរដ្ឋប្បវេណី នៅសាលាដំបូង

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមិនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា **ផុន បុប្ផាធាវី**
កញ្ញា **ហួយ បូផា**

សាស្ត្រាចារ្យណែនាំ
លោក **ញឹក ឧត្តី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២៤ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
**Université Royale de Droit et des Sciences Economiques**
**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# តួនាទីមេធាវីក្នុងនីតិវិធីបណ្តឹងរដ្ឋប្បវេណី នៅសាលាដំបូង

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា **ផុន បុប្ផាធាវី**
កញ្ញា **ហួយ បូផា**

សាស្ត្រាចារ្យណែនាំ
លោក **ញឹក ឧុធ្ធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | ឆ្នាំចូលសិក្សា ២០១៥
ជំនាន់ទី២៤ (អាហារូបករណ៍) | ឆ្នាំសរសេរសារណា ២០១៩

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ផុន បុប្ផាធាវី** និង **ហ្វយ ម្ធា** ជានិស្សិតឆ្នាំទី៤ អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រជំនាន់ទី២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ យើងខ្ញុំទាំងពីរនាក់សូមសម្ដែងនូវការដឹងគុណ និង ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

❖ **អ្នកមានគុណទាំងពីរ និង ក្រុមគ្រួសារ**ដែលបានបង្កើតពួកយើងមកឱ្យបានឃើញពន្លឺថ្ងៃ បានស្គាល់ពិភពលោកដ៏សែនស្រស់បំព្រងមួយនេះ។ លើសពីនេះទៅទៀតលោកទាំងពីរបានខិតខំប្រឹងប្រែង ចំណាយទាំងកម្លាំងកាយទាំងកម្លាំងចិត្ត ពុះពារតស៊ូរាល់ការលំបាកដើម្បីពួកយើង។ លោកទាំងពីរមិនត្រឹមតែបានចិញ្ចឹមបីបាច់ថែរក្សា ផ្ដល់ការអប់រំ និង ផ្គត់ផ្គង់តម្រូវការគ្រប់យ៉ាងដល់ពួកយើងប៉ុណ្ណោះទេ ពួកគាត់ថែមទាំងបានផ្ដល់ឱ្យពួកយើងនូវកម្លាំងចិត្ត ការគាំទ្រ និង សេចក្ដីស្រលាញ់ដែលដ៏ធំធេងមិនអាចវាស់បាន។ ហើយពួកយើងក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះបងប្អូនស្រីប្រុសទាំងអស់ផងដែរ ដែលពួកគាត់តែងតែផ្ដល់ភាពកក់ក្ដៅ ក្ដីស្រលាញ់ ការជំរុញលើកទឹកចិត្ត និងការផ្គត់ផ្គង់ផ្សេងៗដល់ពួកយើង។

❖ **សាកលវិទ្យាធិការ**នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បុគ្គលិក សាស្ត្រាចារ្យ និងបណ្ណារក្សទាំងអស់ដែលតែងតែជួយណែនាំបង្ហាត់បង្រៀនគ្រោះត្រាយផ្លូវ ផ្ដល់ចំណេះដឹង និង ឯកសារស្រាវជ្រាវផ្សេងៗរយៈពេល៤ឆ្នាំមកនេះ។ ហើយពួកយើងក៏សូមថ្លែងអំណរគុណផងដែរដែលសាកលវិទ្យាល័យបានផ្ដល់ឱកាសសម្រាប់ពួកយើងទាំងពីរនាក់ បានមានឱកាសដើម្បីធ្វើការសិក្សាស្រាវជ្រាវ សរសេរសារណាមួយនេះ។

❖ លោកគ្រូសាស្ត្រាចារ្យ **ញឹក ឧុធី** ដែលជាសាស្ត្រាចារ្យណែនាំសរសេរសារណាមួយនេះ។ លោកគ្រូបានជួយណែនាំគ្រោះត្រាយផ្លូវ និង កែលម្អបំពេញបន្ថែមនូវរាល់ចំណុចខ្វះខាតរបស់ពួកយើង។

❖ **មិត្តភក្តិ**របស់ពួកយើងទាំងអស់ដែលតែងតែផ្ដល់ក្ដីស្រលាញ់ ការយកចិត្តទុកដាក់ និង កម្លាំងចិត្តគ្រប់ពេលវេលាទាំងអស់។ លើសពីនេះពួកគេក៏បានជួយផ្ដល់ជាគំនិត និង ឯកសារផ្សេងៗដល់ពួកយើងផងដែរ។

ជាចុងក្រោយ ពួកយើងសូមគោរពជូនពរអ្នកទាំងអស់គ្នាឱ្យជួបតែសេចក្ដីសុខសុភមង្គលក្នុងក្រុមគ្រួសារ ហើយរីកចម្រើនជោគជ័យលើគ្រប់កិច្ចការទាំងអស់និងសូមឱ្យមានសុខភាពល្អមាំមួនជាដរាបតរៀងទៅ។

## អារម្ភកថា

ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចអស់រយៈពេលជាងបីឆ្នាំបានកន្លងផុតទៅ។ អំឡុងពេលនោះ គឺជាពេលដែលពួកយើងបានទទួលនូវចំណេះដឹងនិងការចែករំលែកបទពិសោធន៍ល្អៗពីសំណាក់សាស្ត្រចារ្យដែលជាអ្នកបង្ហាត់បង្រៀនពួកយើង ហើយក្នុងឆ្នាំបញ្ចប់ការសិក្សារបស់ពួកយើងនេះ ពួកយើងក៏បានធ្វើការសម្រេចចិត្តជ្រើសរើសយក ការសរសេរសារណាសម្រាប់ការបញ្ចប់ការសិក្សារបស់ពួកយើង។

ពួកយើងទាំងពីរនាក់សម្រេចចិត្តជ្រើសរើសយកប្រធានបទ " **តួនាទីមេធាវីក្នុងនីតិវិធីបណ្តឹងរដ្ឋប្បវេណីនៅសាលាដំបូង** "មកធ្វើការស្រាវជ្រាវ ពីព្រោះដោយសារតែ យើងយល់ឃើញថា មេធាវីគឺជាវិជ្ជាជីវៈមួយដែលឯករាជ្យ និងបានចូលរួមលើកកម្ពស់នីតិរដ្ឋ និង យុត្តិធម៌សង្គម ហើយជាវិជ្ជាជីវៈមួយដែលមានមនុស្សជាច្រើនប្រាថ្នាចង់បាន ជាពិសេសនិស្សិតច្បាប់មួយចំនួន ហើយក៏រួមទាំងពួកយើងទាំងពីរនាក់ផងដែរ។ ការស្រាវជ្រាវលើប្រធាបទមួយនេះគឺពិតជាមានសារៈសំខាន់ណាស់ ទាំងអ្នកសិក្សាស្រាវជ្រាវទាក់ទងនឹងមេធាវី នីតិតុលាការនៃការវិធីជំនុំជម្រះលើកទី១ និង ជាពិសេសទាក់ទងនឹងតួនាទីរបស់មេធាវីក្នុងនីតិវិធីបណ្តឹងរដ្ឋប្បវេណីនេះតែម្តង។ម្យ៉ាងវិញទៀត ប្រធានបទនេះក៏អាចជាការយល់ដឹងសម្រាប់ប្រជាជនទូទៅផងដែរ ដើម្បីឱ្យបានដឹងអំពីតួនាទីរបស់មេធាវីដែលដើរតួនាទីយ៉ាងសំខាន់ក្នុងបណ្តឹងរដ្ឋប្បវេណី ក្នុងការតំណាងឱ្យដើមចោទ និងចុងចម្លើយនៅក្នុងដំណើរការនីតិវិធីរបស់តុលាការដើម្បីជួយឱ្យដំណើរការនីតិវិធីបណ្តឹងប្រព្រឹត្តទៅបានរលូន ក៏ដូចជាការពារបាននូវផលប្រយោជន៍របស់កូនក្តីផង។

ពួកយើងសង្ឃឹមថា ការស្រាវជ្រាវមួយនេះនឹងរួមចំណែកក្នុងការចែករំលែកចំណេះដឹង និងជាជំនួយមួយផ្នែកតូចដល់សិស្សនិស្សិតជាអ្នកសិក្សាជំនាន់ក្រោយឱ្យបានយល់ដឹងបន្ថែមតាមរយៈប្រធានបទរបស់ពួកយើងនេះ។ ជាចុងក្រោយ ពួកយើងទាំងពីរនាក់ក៏សូមអភ័យទោសទុកជាមុនចំពោះរាល់កំហុសឆ្គងដោយអចេតនាដែលអាចនឹងកើតមាននៅក្នុងអត្ថបទសារណានេះ ហើយពួកយើងក៏ស្វាគមន៍ផងដែរនូវរាល់គំនិតរិះគុណផ្សេងៗដើម្បីស្ថាបនាលើប្រធានបទរបស់ពួកយើងឱ្យកាន់តែល្អបន្ថែមទៀត ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១
១. លំនាំនៃការសិក្សាស្រាវជ្រាវ ........ ១
២. ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ ........ ២
៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ ........ ៣
៤. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ ........ ៣
៥. វិធីសាស្រ្តនៃការសិក្សាស្រាវជ្រាវ ........ ៣
៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤
**ជំពូកទី១៖ អំពីមេធាវី** ........ ៥
**ផ្នែកទី១៖ ប្រវត្តិសាស្ត្រនៃការវិវត្តវិជ្ជាជីវៈមេធាវី** ........ ៥
**ផ្នែកទី២៖ តម្លៃ និងសារសំខាន់នៃមេធាវីនៅក្នុងសង្គម** ........ ៨
**ផ្នែកទី៣៖ ក្របខណ្ឌគតិយុត្តនៃវិជ្ជាជីវៈមេធាវី** ........ ៩
**ផ្នែកទី៤៖ លក្ខន្តិកៈមេធាវី និងនីតិវិធីចូលប្រកបវិជ្ជាជីវៈ** ........ ១០
៤.១. តាមរយៈការប្រឡង ........ ១១
៤.១.១. លក្ខខណ្ឌ ........ ១១
៤.១.២. ការប្រឡង ........ ១១
៤.១.៣. ការចុះកម្មសិក្សា ........ ១២
៤.២. តាមការស្នើសុំ ........ ១២
៤.២.១. លក្ខខណ្ឌ ........ ១២
៤.២.២. ការដាក់ពាក្យសុំ ........ ១២
៤.២.៣. ការដាក់ពាក្យធ្វើកម្មសិក្សា ........ ១៣
**ផ្នែកទី៥៖ ក្រមសីលធម៌វិជ្ជាជីវៈមេធាវី (ការប្រកបវិជ្ជាជីវៈ)** ........ ១៣
៥.១. ឯករាជ្យភាព និងសេរីភាព នៃវិជ្ជាជីវៈមេធាវី ........ ១៤
៥.២. តម្លៃសីលធម៌នៃវិជ្ជាជីវៈមេធាវី ........ ១៤
៥.២.១. សញ្ញាណទូទៅ ........ ១៤
៥.២.២. ការទទួលរឿងក្តី ........ ១៥
៥.២.៣. ការប្រុងប្រយ័ត្ន ........ ១៥
៥.២.៤. សុចរិតភាព និងភាពស្មោះត្រង់ ........ ១៦
៥.២.៥. ការរក្សាការសម្ងាត់នៃវិជ្ជាជីវៈ ........ ១៦

៥.២.៦. ទំនាស់ផលប្រយោជន៍ និងការហាមឃាត់............................................១៧
៥.៣. ការបង់វិភាគទាន........................................................................................ ១៨
**ផ្នែកទី៦៖ សារៈសំខាន់ និង តួនាទីរបស់មេធាវី**.............................................. ១៨
៦.១. បេសកកម្មរបស់មេធាវី .............................................................................. ១៨
៦.២. តួនាទីរបស់មេធាវី........................................................................................ ១៩
៦.២.១. សញ្ញាណទូទៅ............................................................................................ ១៩
៦.៣. ការពិគ្រោះយោបល់ផ្នែកច្បាប់ ................................................................. ១៩
៦.៤. ការផ្ដល់ប្រឹក្សាផ្នែកច្បាប់ ........................................................................... ២០
**ជំពូកទី២៖ តួនាទីមេធាវីក្នុងនីតិវិធីរឿងក្ដីរដ្ឋប្បវេណីនៅសាលាដំបូង**............ ២២
១. នីតិវិធីត្រៀមទាញហេតុផល ........................................................................... ២៣
១.១. ការរៀបចំដាក់ឯកសារត្រៀម........................................................................ ២៤
១.២. ការសាកល្បងផ្សះផ្សាក្នុងនីតិវិធីត្រៀមទាញហេតុផល....................... ២៤
១.៣. ការធ្វើសេចក្ដីថ្លែងការណ៍របស់គូភាគី..................................................... ២៥
១.៤. ការបំភ្លឺចំណុចវិវាទ...................................................................................... ២៦
១.៥. ការពិនិត្យភស្តុតាងជាឯកសារ ................................................................... ២៦
២. ដំណាក់កាលនីតិវិធីទាញហេតុផលផ្ទាល់មាត់ ............................................២៧
២.១. ការសាកល្បងផ្សះផ្សាក្នុងនីតិវិធីទាញហេតុផល ..................................២៧
២.២. ការធ្វើសេចក្ដីថ្លែងការណ៍ពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញ
ហេតុផល ............................................................................................................ ២៨
២.៣. ការដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនថ្មី ......................................... ២៨
២.៤. ពេលបញ្ចប់ការទាញហេតុផលផ្ទាល់មាត់...............................................៣០
៣. ក្រោយពេលសវនាការ.......................................................................................៣០
៣.១. ពន្យល់ពីសិទ្ធិធ្វើបណ្ដឹងឧបាស្រ័យដល់កូនក្ដី........................................៣០
៣.២. ពន្យល់ពីសិទ្ធិធ្វើបណ្ដឹងសុំអនុវត្តសាលក្រម ..........................................៣១
**សេចក្ដីសន្និដ្ឋាន** ......................................................................................... ៣២
**អនុសាសន៍** ......................................................................................................៣៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំនៃការសិក្សាស្រាវជ្រាវ

វិជ្ជាជីវៈមេធាវី បានកកើតឡើងនៅក្នុងសង្គមកម្ពុជាអស់រយៈពេល ជាច្រើនឆ្នាំមកហើយ។ វិជ្ជាជីវៈនេះបានចូលរួមពង្រឹងវិស័យយុត្តិធម៌ ក្នុងសង្គមលើកកម្ពស់នីតិរដ្ឋ និងលិទ្ធិប្រជាធិបតេយ្យ នៅក្នុងប្រទេសកម្ពុជាយើងផងដែរ។ដោយសារប្រទេសកម្ពុជា បានឆ្លងកាត់នូវសង្គ្រាមស៊ីវិលរ៉ាំរ៉ៃជាច្រើនទសវត្សន៍នោះ ទើបធ្វើឱ្យវិជ្ជាជីវៈមេធាវីត្រូវបានបាត់បង់មួយរយៈហើយអ្នកចេះដឹងផ្នែកច្បាប់ក៏ត្រូវបានសម្លាប់ស្ទើរគ្មានសល់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ វិជ្ជាជីវៈនេះបានកកើតឡើងវិញនៅក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩ ហើយដែលបានបង្កើតឡើងវិញជាផ្លូវការដោយមានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាប័នគ្រប់គ្រងដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវីឆ្នាំ១៩៩៥ ហើយក្រោយមក វិធានគ្រប់គ្រងវិជ្ជាជីវៈមេធាវីចំនួន២ផ្សេងទៀតត្រូវបានអនុម័តដោយក្រុមប្រឹក្សា គណៈមេធាវីនៅ ឆ្នាំ១៩៩៥ ផងដែរ គឺបទបញ្ជាផ្ទៃក្នុងនៃគណៈមេធាវី និងក្រមសីលធម៌មេធាវី។

ដោយសារតែព្រះរាជាណាចក្រកម្ពុជាយើង មានការរីកចម្រើនលូតលាស់គ្រប់វិស័យដែលក្នុងនោះមានជាអាទិ៍ ការរីកចម្រើនក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គម និង វិស័យយុត្តិធម៌ ទើបធ្វើឱ្យវិជ្ជាជីវៈមេធាវីមានការរីកចម្រើនជាបន្តបន្ទាប់ដែរ។ ដើម្បីធានានូវរបៀបរៀបរយនៃការប្រកបវិជ្ជាជីវៈមេធាវី និង ជាពិសេសធានាឱ្យបាននូវ សេចក្តីថ្លៃថ្នូរ ឯករាជ្យភាព សេរីភាព នៃវិជ្ជាជីវៈមេធាវី និង ទទួលបានទំនុកចិត្តខ្ពស់ពីអតិថិជនផងនោះ គណៈមេធាវីបានធ្វើការអនុម័តនិងប្រកាសឱ្យប្រើប្រាស់ ក្រមសីលធម៌មេធាវីនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ២០១២។ លើសពីនេះទៅទៀតក្រុមប្រឹក្សានៃគណៈមេធាវី ក៏បានធ្វើការអនុម័តទៅលើសេចក្តីសម្រេចដាក់ឱ្យអនុវត្តនីតិវិធីនៃការទទួលពិនិត្យ និង សម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា៣២ នៃលក្ខន្តិកៈមេធាវីនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ ដើម្បីធ្វើការជំណត់ឱ្យបានច្បាស់លាស់ពីលក្ខខណ្ឌ និងនីតិវិធីនៃការស្នើសុំចូលប្រកបវិជ្ជាជីវៈមេធាវីដោយមិនឆង្លកាត់ការប្រឡងផងដែរ។

មេធាវីដើរតួនាទីយ៉ាងសំខាន់ទាំងក្នុងបណ្តឹងរដ្ឋប្បវេណី និង បណ្តឹងព្រហ្មទណ្ឌក្នុងការការពារដើមចោទ និងចុងចម្លើយ។មិនត្រឹមតែប៉ុណ្ណោះ មេធាវីគឺជាតំណាងដ៏សំខាន់ម្នាក់ក្នុង បណ្តឹងទាំងពីរ។ ដោយឡែក ពួកយើងមានការចាប់អារម្មណ៍ខ្លាំងចំពោះតួនាទីមេធាវីក្នុងនីតិវិធីរដ្ឋប្បវេណីដូចនេះ ពួកយើងនឹងលើកយកតែតួនាទីមេធាវីក្នុងបណ្តឹងរដ្ឋប្បវេណីមកសិក្សាតែប៉ុណ្ណោះ។នៅក្នុងសង្គមបច្ចុប្បន្ន រឿងក្តីរដ្ឋវេណីត្រូវបានកើតឡើងជារៀងរាល់ថ្ងៃ ដែលវាជារឿងឯកជនដែលបុគ្គល

នៃជម្លោះគឺត្រូវការមានការពិភាក្សាយោបល់ផ្នែកច្បាប់ពីអ្នកច្បាប់ ជាពិសេសគឺពីមេធាវី។ មេធាវីដើរតួយ៉ាងសំខាន់ ក្នុងរឿងក្ដី ឯកជន ដោយសារតែរឿងក្ដីរដ្ឋប្បវេណី មិនមានការចូលរួមជួយពីរដ្ឋឡើយ បើមិនមានការ ដាក់បណ្ដឹងពីប្រជាពលរដ្ឋ ដែលជាដើមបណ្ដឹង និង ចុងចម្លើយ។

តួនាទីមេធាវី ក្នុងការតំណាងដោយអាណត្តិឱ្យកូនក្ដីរបស់ខ្លួនគឺបានផ្ដល់សារៈប្រយោជន៍ជាច្រើន ទាំងចំពោះគូភាគីផ្ទាល់និង ទាំងជួយសម្រួលដំណើរការប្រព្រឹត្តិទៅនៃនីតិវិធីរបស់តុលាការ ព្រោះថាមេធាវី គឺជាអ្នកច្បាប់ដែលមានការយល់ដឹងទាំងច្បាប់ទម្រង់និងច្បាប់សារធាតុដោយប្រើប្រាស់វិធីតាមផ្លូវច្បាប់ដើម្បីការពារផលប្រយោជន៍កូនក្ដី។ របាយការណ៍ស្រាវជ្រាវនេះ យើងនឹងធ្វើការសិក្សាពី តួនាទីរបស់មេធាវីនៅក្នុងនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីក្នុងនាមជាតំណាងដោយអាណត្តិអោយកូនក្ដី(មានលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ) នៅក្នុងដំណើរការនីតិវិធីរដ្ឋប្បវេណីនៅសាលាដំបូង។

## ២. ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ

ប្រជាជនជាទូទៅច្រើនតែដឹងថាមេធាវីគឺជាអ្នកចេះដឹងជ្រៅជ្រះខាងផ្នែកច្បាប់ជាជំនួយដល់គូភាគីនៅពេលដែលគេចង់ធ្វើការដាក់ពាក្យបណ្ដឹង ដើម្បីទាមទារអ្វីមួយនៅតុលាការ តែភាគច្រើនយើងមិនសូវបានយល់ដឹងស៊ីជម្រៅអំពីតួនាទី និងភារកិច្ចរបស់មេធាវីថាមានអ្វីខ្លះនោះទេ ហើយរឹតតែមិនបានយល់ពីលំហូរនៃនីតិវិធីនៃតុលាការរដ្ឋប្បវេណី និងកិច្ចការរបស់មេធាវីនៅក្នុងដំណើរការរឿងក្ដីរដ្ឋប្បវេណីមួយ ខណៈពេលដែលវាគឺជារឿងមួយសំខាន់ដែលយើងគួរតែស្វែងយល់ឲ្យបានចេះដឹង។ការសិក្សាស្វែងយល់ពីតួនាទីរបស់មេធាវីនៅក្នុងនីតិវិធីរឿងក្ដីរដ្ឋប្បវេណីគឺពិតជាមានភាពចាំបាច់ណាស់សម្រាប់ អ្នកសិក្សាស្រាវជ្រាវនិងប្រជាពលរដ្ឋទូទៅគ្រប់ស្រទាប់វណ្ណៈ ពីព្រោះមេធាវីគឺដើរតួយ៉ាងសំខាន់នៅក្នុងនីតិវិធីរដ្ឋប្បវេណី ជាជំនួយដែលប្រជាពលរដ្ឋត្រូវការដើម្បីជួយពួកគេក្នុងការប្ដឹងទាមទារសិទ្ធិអ្វីមួយរបស់ពួកគេដូចនេះពេលមានបញ្ហាកើតឡើងពួកគេអាចមានដំណោះស្រាយដ៏សមស្របមួយ ដោយផ្អែកលើការយល់ដឹងរបស់ពួកគេបាន។ ហេតុដូចនេះហើយ ទើបការសិក្សាស្រាវជ្រាវរបស់ពួកយើង គឺធ្វើឡើងដោយមានចំណោទបញ្ហាសំខាន់មួយចំនួន ដូចជា៖

- តើមេធាវីជានរណា?
- តើវិជ្ជាជីវៈមេធាវីកើតឡើងយ៉ាងដូចម្ដេច? ហើយមានការវិវត្តន៍យ៉ាងដូចម្ដេច?
- តើត្រូវមានលក្ខណៈសម្បត្តិនិង គុណសម្បត្តិអ្វីខ្លះទើបអាចក្លាយជាមេធាវី?
- តើត្រូវធ្វើយ៉ាងណាទើបអាចចូលប្រកបវិជ្ជាជីវៈមេធាវីបាន?
- តើលំហូរនៃនីតិវិធីរដ្ឋប្បវេណីនៅសាលាដំបូងមានលក្ខណៈយ៉ាងណាដែរ?
- តើមេធាវីមានតួនាទីអ្វីខ្លះ នៅក្នុងលំហូរនៃនីតិវិធីបណ្ដឹងរដ្ឋប្បវេណីនៅសាលាដំបូង?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

គោលបំណងសំខាន់ៗ នៅក្នុងការសិក្សាស្រាវជ្រាវមួយនេះគឺ មានដូចជាៈ

- ដើម្បីឱ្យបានយល់ដឹងពីរបៀបនិងមធ្យោបាយដើម្បីក្លាយជាមេធាវីនិងការចូលប្រកបវិជ្ជាជីវៈមេធាវីប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ

- ដើម្បីធ្វើការសិក្សាស្វែងយល់ឲ្យបានស៊ីជម្រៅអំពីតួនាទីរបស់មេធាវីនៅក្នុងនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីនៅពេលជំនុំជំរះលើកទី១

- ដើម្បីស្វែងយល់អំពីកិច្ចការដែលមេធាវីត្រូវបំពេញ នៅពេលដែលមានការប្រគល់សិទ្ធិតំណាងដោយអាណត្តិពីកូនក្ដីក្នុងរឿងក្ដីរដ្ឋប្បវេណី

- ដើម្បីស្វែងយល់ ពីលំហូរនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីនៅសាលាដំបូង ចាប់តាំងពីការដាក់ពាក្យបណ្ដឹង រហូតដល់ការប្រកាសសាលក្រម

- ស្វែងយល់អំពីការទទួលខុសត្រូវរបស់មេធាវី ចំពោះកូនក្ដីរបស់ខ្លួននៅក្នុងនីតិវិធីរឿងក្ដីរដ្ឋប្បវេណីនៅសាលាដំបូង

- ដើម្បីទុកជាឯកសារជំនួយដល់អ្នកសិក្សាស្រាវជ្រាវ ក៏ដូចជាសាធារណជនទាំងឡាយគ្រប់មជ្ឈដ្ឋានដើម្បីធ្វើការសិក្សាស្វែងយល់បន្ថែមពីតួនាទីរបស់មេធាវីក្នុងនីតិវិធីនៃការជំនុំជម្រះលើកទី១នៃរឿងក្ដីរដ្ឋប្បវេណី។

## ៤. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ

របាយការណ៍សិក្សាស្រាវជ្រាវនេះ គឺពួកយើងបានធ្វើការសិក្សាស្រាវជ្រាវដោយផ្ដោតសំខាន់ទៅលើមេធាវី និង តួនាទីរបស់មេធាវីក្នុងនីតិវិធីរដ្ឋប្បវេណីនៅសាលាដំបូង។ ពួកយើងនឹងធ្វើការបកស្រាយតែទាក់ទងទៅនឹងលក្ខន្តិកៈមេធាវី និង ការប្រកបវិជ្ជាជីវៈមេធាវី ដែលមានចែងក្នុងច្បាប់ស្ដីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៥ ក្រមសីលធម៌មេធាវីឆ្នាំ២០១២និង តួនាទីរបស់មេធាវី នៅក្នុងនីតិវិធីនៃការជំនុំជម្រះលើកទី១ ដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៦តែប៉ុណ្ណោះ ដោយយោងតាម ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ នេះ និងបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៦ ដែលយើងកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ននេះប៉ុណ្ណោះ។

## ៥. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

របាយការណ៍សិក្សាស្រាវជ្រាវនេះគឺបានកើតចេញមកពីការសិក្សាតាមបែបទ្រឹស្ដីផង និងបែបវិភាគទៅលើការអនុវត្តន៍ជាក់ស្ដែងផង។ ចំណែកប្រភពឯកសារសំខាន់ៗដែលប្រើប្រាស់ក្នុងការធ្វើ

របាយការណ៍ស្រាវជ្រាវនេះគឺមានដូចជាក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៥ ក្រមសីលធម៌មេធាវីឆ្នាំ ២០១២ បទបញ្ជាផ្ទៃក្នុងគណៈមេធាវីឆ្នាំ២០១៦ និង ឯកសារពិគ្រោះផ្សេងៗទៀតដែលចងក្រងដោយសាស្ត្រាចារ្យច្បាប់ដែលពួកយើងធ្លាប់បានរៀនជាមួយ។ មិនត្រឹមតែប៉ុណ្ណោះ ពួកយើងក៏បានធ្វើការសាកសួរសុំការបំភ្លឺណែនាំពីអ្នកដែលគាត់ធ្វើការអនុវត្តផ្ទាល់ចំពោះភារកិច្ចទាំងនោះ ដើម្បីធ្វើយ៉ាងណាឱ្យប្រាកដថារបាយការណ៍សិក្សាស្រាវជ្រាវមួយនេះមានភាពត្រឹមត្រូវនិងដូចនឹងការអនុវត្តជាក់ស្តែង។

### ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

របាយការណ៍ស្រាវជ្រាវនេះ ចែកចេញជាពីរជំពូកគឺៈ

ជំពូកទី ១ៈ អំពីមេធាវី។

ជំពូកទី ២ៈ តួនាទីមេធាវីនៅក្នុងនីតិវិធីរឿងក្តីរដ្ឋប្បវេណីក្នុងសាលាដំបូង។

# ជំពូកទី ១
# អំពីមេធាវី

# ជំពូកទី ១
# អំពីមេធាវី

## ផ្នែកទី១៖ ប្រវត្តិសាស្ត្រនៃការវិវត្តវិជ្ជាជីវៈមេធាវី

សញ្ញាណនៃមេធាវី បានចាប់ផ្ដើមលេចឡើងចាប់តាំងពីសតវត្សន៍ទី៥ នៅឯទីក្រុងអាតែន ប្រទេសក្រិច។ នាសម័យនោះ មេធាវី គឺជាអ្នកប្រកបរបរដោយសេរីក្នុងការជជែកពិភាក្សា ដើម្បីឈ្នះ និងដើម្បីផលប្រយោជន៍ ហើយក៏មិនមែនដើម្បីការពារសិទ្ធិដល់អតិថិជនណាមួយ ឬ ធ្វើការលើកកម្ពស់តម្លៃនៃសីលធម៌ ឬ យុត្តិធម៌ឡើយ។ ចាប់តាំងពីពេលនោះមក តម្លៃនិងសារសំខាន់នៃមេធាវីត្រូវបានផ្សព្វផ្សាយនៅទូទាំងពិភពលោក។ ទោះជាយ៉ាងណាក៏ដោយសញ្ញាណនៃមេធាវីទើបតែបាននាំចូលមកប្រទេសកម្ពុជាក្នុង រយៈពេលថ្មីៗនេះប៉ុណ្ណោះ។ដោយហេតុថា តាមប្រពៃណីប្រទេសកម្ពុជា រាល់ទំនាស់ត្រូវបានដោះស្រាយផ្សះផ្សាក្នុងលក្ខណៈមិនផ្លូវការដោយព្រះមហាក្សត្រ មេភូមិ ព្រះសង្ឃ ឬអ្នកជិតខាងដែលមានចំណេះដឹងខ្ពស់ជាងដោះស្រាយ ឬផ្សះផ្សាក្នុងលក្ខណៈផ្លូវការដោយចៅក្រមនិងមានការការពារពីមេធាវី។

នៅក្នុងឆ្នាំ១៩៣២ មានការណែនាំឱ្យស្គាល់ជាផ្លូវការនូវវិជ្ជាជីវៈមេធាវីនៅក្នុងប្រទេសកម្ពុជា ដោយព្រះរាជប្រកាសលេខ៣២ ចុះថ្ងៃទី១៥ មីនាឆ្នាំ១៩៣២ ដែលក្រោយមកត្រូវបានធ្វើវិសោធនកម្មដោយព្រះរាជក្រមលេខ៦៤៨ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៥១។ ព្រះរាជប្រកាសលេខ៣២បានណែនាំឱ្យស្គាល់នូវ"ស្មាក្តី"និងអ្នកដែលអនុវត្តវិជ្ជាជីវៈនេះត្រូវបានហៅថា"អ្នកថណាយក្តី"។

វិជ្ជាជីវៈមេធាវីប្រទេសកម្ពុជាបានទទួលរងនូវការវិវត្តយ៉ាងដុនដាប ដោយសារមានការផ្លាស់ប្តូរនយោបាយនិងសង្គមច្រើនដងនៅក្នុងប្រទេសកម្ពុជា។ តម្រូវការសេវារបស់មេធាវី មានការអភិវឌ្ឍឡើង ដោយសារតែការកើនឡើងនៃការងារវិនិយោគ និងសកម្មភាពពាណិជ្ជកម្ម ភាពស្មុគស្មាញនៃប្រព័ន្ធច្បាប់ និងនីតិវិធីរបស់តុលាការ និងការកើនឡើងនៃវិវាទ។ សិទ្ធិក្នុងការទទួលបានការការពារផ្នែកច្បាប់ដ៏ពេញលេញ និងការជុំនុំជម្រះក្តី ប្រកបដោយយុត្តិធម៌ត្រូវបានដាក់បញ្ចូលទៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។ ក្នុងឆ្នាំ១៩៤៧ ប្រទេសកម្ពុជាបានអនុម័តរដ្ឋធម្មនុញ្ញទី១ របស់ខ្លួន ដែលបានទទួលស្គាល់សិទ្ធិរបស់ជនគ្រប់រូប ហើយការចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនអាចធ្វើទៅបានលុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។ ការចាប់ខ្លួនត្រូវផ្អែកតាមនីតិវិធីដែលកំណត់នៅក្នុងច្បាប់ហើយមានមូលដ្ឋានជាក់លាក់ និងសម្រេចដោយតុលាការ។ រដ្ឋធម្មនុញ្ញនេះបានទទួលស្គាល់ផងដែរនូវសិទ្ធិជាមូលដ្ឋានផ្សេងៗទៀតរបស់មនុស្ស។ កាន់តែច្បាស់ជាងនេះទៅទៀត រដ្ឋធម្មនុញ្ញទី២ នៅឆ្នាំ១៩៧២ បានចែងពីសិទ្ធិរបស់ជន

គ្រប់រូបក្នុងការការពារខ្លួនតាមផ្លូវតុលាការ។[1] ជាអកុសល សិទ្ធិជាមូលដ្ឋានទាំងនេះ ត្រូវបានលុបបំបាត់នៅក្នុងអំឡុងពេល នៃរបបកម្ពុជាប្រជាធិបតេយ្យ។ ចាប់តាំងពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាទាំងអស់បាត់បង់ នូវសិទ្ធិក្នុងការការពារខ្លួនតាមផ្លូវតុលាការ។ ការដាក់ទណ្ឌកម្មនានា និងការប្រហារជីវិតត្រូវបានយកមកអនុវត្តតាមការសម្រេចរបស់មេអង្គការ[2]ដោយមិនមានការជំនុំជម្រះតាមផ្លូវតុលាការឡើយ។ សិទ្ធិក្នុងការទទួលបានការការពារតាមផ្លូវច្បាប់ត្រូវបានកើតឡើងម្តងទៀតក្នុងឆ្នាំ ១៩៨១ដោយរដ្ឋធម្មនុញ្ញទី៥[3] ដែលអនុម័តដោយរដ្ឋសភាប្រជាជនកម្ពុជានៃសាធារណប្រជាមានិតកម្ពុជា នាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១ និងត្រូវបានប្រកាសសាធារណៈនៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ១៩៨១។ ទោះបីជាយ៉ាងណាក៏ដោយ ការអនុវត្តសិទ្ធិទាំងនេះស្ទើរតែមិនអាចធ្វើទៅបាន បន្ទាប់ពីមានការរំដោះនៅឆ្នាំ១៩៧៩ ដោយសារតែមេធាវីជាច្រើនបានត្រូវគេសំលាប់ចោល ហើយអ្នកចេះដឹងវិស័យច្បាប់នៅសល់តិចតួចបំផុត។

ការចាត់តាំងមេធាវីបានចាប់ផ្តើម បន្ទាប់ពីមានការបង្កើតតុលាការខេត្ត-ក្រុងបដិវត្តប្រជាជនក្នុងឆ្នាំ១៩៧៩[4] តុលាការកំពូលក្នុងឆ្នាំ១៩៨៥ និងសាលាឧទ្ធរណ៍ក្នុងឆ្នាំ១៩៩២។ នាឆ្នាំ១៩៩២ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ដែលមានការជួយជ្រោមជ្រែងពីអាជ្ញាធរ បណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិក្នុងប្រទេសកម្ពុជាបានអនុម័តបទប្បញ្ញត្តិពាក់ព័ន្ធនឹងច្បាប់ព្រហ្មទណ្ឌ និងច្បាប់យុត្តាធិការព្រមទាំងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅក្នុងប្រទេសកម្ពុជា ក្នុងអំឡុងពេលអន្តរកាលដែលមានឈ្មោះថា "បទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់ អនុវត្តនៅក្នុងប្រទេសកម្ពុជាក្នុងសម័យអន្តរកាល" ដែលគេហៅកាត់ថា ("ច្បាប់ព្រហ្មទណ្ឌអន្តរកាល")។ ច្បាប់ព្រហ្មទណ្ឌអន្តរកាលបានផ្តល់នូវលទ្ធភាពក្នុង ការបង្កើតគណៈមេធាវី និងសិទ្ធិរបស់ជនជាប់ចោទក្នុងការមានមេធាវីជាតំណាង និងការពារសិទ្ធិនៅក្នុងដំណើរការជុំនុំជម្រះក្តី។[5] នៅក្នុងអំឡុងពេលអន្តរកាលបុគ្គលដែល មានសញ្ញាប័ត្រយ៉ាងហោចណាស់ ដែលមានតម្លៃស្មើទៅនឹងសញ្ញាប

[1] មាត្រា៦ នៃរដ្ឋធម្មនុញ្ញ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧២

[2] អង្គការ សំដៅដល់អង្គភាពរដ្ឋបាល នៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។

[3] មាត្រា៨៥ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៨១។

[4] ចាប់ពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ១៩៨៥ តុលាការមានតែ១ថ្នាក់ប៉ុណ្ណោះ គឺនៅខេត្ត-ក្រុង ហើយសេចក្តីសម្រេចតុលាការ ត្រូវមានការពិនិត្យពីក្រសួងយុត្តិធម៌ និងប្រសិនបើរកឃើញថាមានកំហុសសេចក្តីសម្រេចនោះនឹងត្រូវបញ្ជូនទៅក្រុមប្រឹក្សារដ្ឋដើម្បីសម្រេចជាលើកចុងក្រោយ យោងតាមច្បាប់ស្តីពីការរៀបចំតុលាការ និងនាយកដ្ឋានអយ្យការ ប្រកាសឱ្យប្រើដោយក្រឹត្យលេខ ០២ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២។

[5] មាត្រា៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

ត្របរិញ្ញាបត្រនីតិសាស្រ្ត ឬមានបទពិសោធន៍ ៥ ឆ្នាំក្នុងវិស័យច្បាប់ ឬវិស័យតុលាការ អាចត្រូវបាន អនុញ្ញាតឱ្យអនុវត្ត វិជ្ជាជីវៈមេធាវី។ សិទ្ធិក្នុងការទទួលបានការតំណាង និងការពារសិទ្ធិរបស់ជន ជាប់ចោទនៅក្នុងដំណើរការជុំនុំជម្រះក្តី មិនមែនមានត្រឹមតែនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាល ឆ្នាំ ១៩៩២ ប៉ុណ្ណោះទេ រដ្ឋធម្មនុញ្ញទី៥នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ក៏បានបញ្ជាក់ទទួលស្គាល់ សិទ្ធិនេះផងដែរ។ [6] រដ្ឋធម្មនុញ្ញបែបប្រជាធិបតេយ្យមួយនេះបានទទួលស្គាល់នូវការការពារសិទ្ធិជា មូលដ្ឋានរបស់មនុស្ស ដូចដែលបានប្រកាសនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ និងនៅក្នុង សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្សក្នុងឆ្នាំ១៩៤៨ និងក្នុងអនុសញ្ញា កតិកាសញ្ញា និងសន្ធិ សញ្ញាអន្តរជាតិ ដទៃទៀត។[7] លើសពីនេះ សិទ្ធិមានមេធាវី ក៏មានចែងកំណត់ផងដែរនៅក្នុងច្បាប់ ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣។[8]

ថ្វីត្បិតតែមានវត្តមាននៃច្បាប់ ដែលបានទទួលស្គាល់សិទ្ធិក្នុងការទទួលបាន ការការពារ និងមានការបង្កើតនូវវិជ្ជាជីវៈមេធាវីក៏ដោយ ក៏មេធាវីមិនត្រូវបានអនុញ្ញាត ឱ្យអនុវត្តវិជ្ជាជីវៈជាលក្ខ ណៈឯកជននៅក្រៅតុលាការដែរ នៅខណៈពេលដែលមិនមានច្បាប់ ស្តីពីលក្ខន្តិកៈមេធាវី ពោលគឺ មេធាវីអាចធ្វើត្រឹមតែជាអ្នកការពារក្តីប៉ុណ្ណោះ។ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ត្រូវបានអនុម័តចប់សព្វ គ្រប់ដោយរដ្ឋសភានៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៥ ហើយបានប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខនស/រកម/ ០៨៩៥/ ០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥។ គណៈមេធាវីនៃព្រះរាជាណាចក្រ កម្ពុជា បានកើតចេញជារូបរាងឡើង និងចាប់ផ្តើមដំណើរការជាផ្លូវការ នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ ១៩៩៥ តាមរយៈមហាសន្និបាតលើកទី១ របស់ខ្លួន ដោយមានវត្តមានមេធាវីចំនួន៣០រូប ដើម្បីធ្វើ ការបោះឆ្នោតជ្រើសតាំងប្រធានគណៈមេធាវីសម្រាប់ដឹកនាំគណៈមេធាវី និងសមាជិកក្រុមប្រឹក្សាគ ណៈមេធាវីសម្រាប់គ្រប់គ្រងគណៈមេធាវី។ ចាប់តាំងពីពេលនោះមក ចំនួនមេធាវី បានកើនឡើងជា លំដាប់ស្របទៅតាមតម្រូវការមេធាវីក្នុងការធានាការពារសិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់មនុស្ស ដើម្បីធានាបាននូវសិទ្ធិទទួលបានយុត្តិធម៌សម្រាប់ប្រជាពលរដ្ឋគ្រប់រូប និង ដើម្បីពង្រឹងវិស័យ យុត្តិធម៌នៅក្នុងសង្គមកម្ពុជាទាំងមូល។យើងក៏បានកត់សម្គាល់ផងដែរថា ចំនួនមេធាវីពីមួយឆ្នាំទៅ មួយឆ្នាំគឺមានការកើនឡើងជាបន្តបន្ទាប់ ដោយនៅខែសីហា ឆ្នាំ២០១៦ មេធាវីពេញសិទ្ធិដែល ប្រកបវិជ្ជាជីវៈមាន ចំនួន៨៧៨រូប មេធាវីមិនប្រកបវិជ្ជាជីវៈមានចំនួន៥៩រូប មេធាវីដែលត្រូវហាម

[6] មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣

[7] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣

[8] មាត្រា ៧៥ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៣

ឃាត់មិនឱ្យប្រកបវិជ្ជាជីវៈមានចំនួន២រូប មេធាវីដែលត្រូវបានផ្អាកពីមុខងារជាបណ្តោះអាសន្នមានចំនួន៣រូប និងមេធាវីកម្មសិក្សាមានចំនួន១៧៩រូប[9] និងក្នុងឆ្នាំ២០១៩នេះចំនួនមេធាវីសរុបបានកើនឡើងដល់១៧៧៣នាក់[10]។

## ផ្នែកទី២៖ តម្លៃ និងសារសំខាន់នៃមេធាវីនៅក្នុងសង្គម

មាត្រា១ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីបានចែងថា "វិជ្ជាជីវៈមេធាវីជាវិជ្ជាជីវៈឯករាជ្យ និងសេរី ដែលចូលរួមបម្រើវិស័យយុត្តិធម៌។ វិជ្ជាជីវៈមេធាវីប្រព្រឹត្តទៅបានតែក្នុងក្របខ័ណ្ឌនៃគណៈមេធាវី។"

នៅក្នុងសង្គមបច្ចុប្បន្ននេះ មេធាវីមិនមែនដើរតួត្រឹមតែជាអ្នកតំណាង និងអ្នកជួយការពារក្តីប៉ុណ្ណោះទេ មេធាវីក៏បានដើរតួយ៉ាងសំខាន់ផងដែរ ក្នុងការបង្កើតវិធានច្បាប់នៅក្នុងសង្គម។ មេធាវីគឺជាអ្នកអប់រំ និងជាអ្នកផ្តល់យោបល់លើគ្រប់វិស័យ។ ជាងនេះទៅទៀត សារសំខាន់នៃមេធាវី គឺចូលរួមជួយដល់ក្របខ័ណ្ឌគតិយុត្តនៃការវិនិយោគ និង ការពារផលប្រយោជន៍របស់វិនិយោគិនដែលជាផ្នែកមួយនៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសជាតិ។

ដោយមើលឃើញពីតួនាទីដ៏សំខាន់របស់មេធាវីបែបនេះ ការអនុវត្តវិជ្ជាជីវៈមេធាវីត្រូវតែស្ថិតនៅក្រោមការគ្រប់គ្រងដោយវិធានគតិយុត្ត និង វិធានសីលធម៌វិជ្ជាជីវៈមួយ។ វិធានទាំងនោះនឹងធានានូវការប្រកួតប្រជែងដោយស្មោះត្រង់និងដោយថ្លៃថ្នូរក្នុងចំណោមមេធាវីទាំងអស់។ គ្រប់ទំនាក់ទំនងរវាងសហភាតាមេធាវីត្រូវប្រព្រឹត្តដោយសេចក្តីថ្លៃថ្នូរ សម្បជញ្ញៈ ភាពទៀងត្រង់ មនុស្សធម៌ ស្មារតីឯករាជ្យជាមួយទេព្យកោសល្យដ៏ប៉ិនប្រសប់ គួរសមជានិច្ច និងដោយគោរពវិធានវិជ្ជាជីវៈរបស់ខ្លួន។វិជ្ជាជីវៈមេធាវីមានលក្ខណៈខុសពីវិជ្ជាជីវៈសេរីដទៃ ដូចជាវិជ្ជាជីវៈវេជ្ជសាស្ត្រ គណនេយ្យ ឬវិស្វករជាដើម។ វិជ្ជាជីវៈមេធាវី មានគោលការណ៍ និងតម្លៃរបស់ខ្លួនដាច់ដោយឡែក ដូចដែលបានបង្ហាញនៅលើនិមិត្តសញ្ញានៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា។ និមិត្តសញ្ញានេះតំណាងឱ្យព្រះវិស្ណុ ដែលជាអាទិទេពការពារពិភពលោក ប្រឆាំងនឹងបិសាច។ នៅលើនិមិត្តសញ្ញាព្រះវិស្ណុកាន់វត្ថុផ្សេងៗដោយដៃទាំងប្រាំបីរបស់ទ្រង់ ហើយវត្ថុនីមួយៗ តំណាងឱ្យតម្លៃផ្សេងៗគ្នា។ តម្លៃនៃដៃនីមួយៗគឺសំខាន់ណាស់សម្រាប់ការអនុវត្តវិជ្ជាជីវៈមេធាវីដោយសេរី និងឯករាជ្យ។ មេធាវីទទួលបាន នូវបុព្វសិទ្ធិ និងសេរីភាពពេញលេញក្នុងការបញ្ចេញមតិ នៅក្នុងការអនុវត្តវិជ្ជាជីវៈរបស់

[9] សៀវភៅវិជ្ជាជីវៈមេធាវីក្នុងសង្គមកម្ពុជា ដោយ មេធាវី ប៊ុន ហុន ឆ្នាំ២០១៦

[10] https://www.bakc.org.kh/index.php/2017-07-24-08-31-04

ខ្លួនដើម្បីការពារផលប្រយោជន៍ ផ្នែកច្បាប់របស់អតិថិជន។ ទោះបីជាយ៉ាងណាក៏ដោយ មេធាវីមានកាតព្វកិច្ចអនុវត្តវិជ្ជាជីវៈរបស់ខ្លួនប្រកបដោយ សេចក្តីថ្លៃថ្នូរ សម្បជញ្ញៈ សុចរិត មនុស្សធម៌ និងឯករាជ្យដូចដែលមានចែងក្នុង ក្រមសីលធម៌មេធាវី។

**ផ្នែកទី៣៖ ក្របខណ្ឌគតិយុត្តនៃវិជ្ជាជីវៈមេធាវី**

នៅក្នុងប្រទេសកម្ពុជា វិជ្ជាជីវៈមេធាវីត្រូវបានគ្រប់គ្រងដោយច្បាប់ស្តីពី លក្ខន្តិកៈមេធាវីដែលបានប្រកាសឱ្យប្រើនៅ ថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ បទបញ្ជាផ្ទៃក្នុងគណៈមេធាវី ដែលត្រូវបានសម្រេចអនុម័តដោយក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៩៥ និងក្រមសីលធម៌មេធាវី ដែលបានសម្រេចអនុម័តដោយក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៩៥ ហើយត្រូវបានតែងតាំង និងសម្រេចអនុម័ត ជាថ្មីឡើងវិញនាសម័យប្រជុំរបស់ក្រុមប្រឹក្សាគណៈមេធាវីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២ ព្រមទាំងបទប្បញ្ញត្តិ និងសេចក្តីសម្រេចដទៃទៀត ដែលចេញដោយក្រុមប្រឹក្សាគណៈមេធាវី។

ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បង្កើតឱ្យមាននូវរចនាសម្ព័ន្ធ និងកិច្ចដំណើរការនៃវិជ្ជាជីវៈមេធាវី និងផ្តល់នូវអំណាចផ្តាច់មុខដល់គណៈមេធាវីក្នុងការគ្រប់គ្រងវិជ្ជាជីវៈ។ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីមានបញ្ចូលនូវបទបញ្ញត្តិ ស្តីពីតួនាទីរបស់មេធាវី តួនាទីរបស់ប្រធាននិងក្រុមប្រឹក្សាគណៈមេធាវី និងការជ្រើសតាំងប្រធាន និងក្រុមប្រឹក្សាគណៈមេធាវី អាណត្តិរបស់ប្រធាន និងក្រុមប្រឹក្សាគណៈមេធាវី រចនាសម្ព័ន្ធនៃមហាសន្និបាតសាមញ្ញ និងមហាសន្និបាតវិសាមញ្ញ វិធាន និងលក្ខខណ្ឌក្នុងការអនុវត្តវិជ្ជាជីវៈមេធាវីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ងារជាមេធាវីកិត្តិយស ទណ្ឌកម្មជាបទវិន័យ ការកំណត់កម្រៃ វិជ្ជាជីវៈរបស់មេធាវី ការបង់ភាគទានចូលទៅក្នុងមូលនិធិ នៃគណៈមេធាវី គណនេយ្យ និងការធានារ៉ាប់រង ការទទួលខុសត្រូវរបស់មេធាវីក្នុងការប្រកបវិជ្ជាជីវៈ។

បទបញ្ជាផ្ទៃក្នុងគណៈមេធាវី កំណត់នូវវិធានដែលរួមមាន វិធានវិជ្ជាជីវៈមេធាវី មហាសន្និបាត គណៈមេធាវី ក្រុមប្រឹក្សាគណៈមេធាវី ជំនួយសង្គ្រោះតាមផ្លូវតុលាការ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ការរៀបចំកម្មសិក្សា ការគ្រប់គ្រងមូលនិធិ និងប្រាក់តម្កល់ទុក កាតព្វកិច្ចគណនេយ្យ និងការត្រួតពិនិត្យ។

ក្រមសីលធម៌មេធាវី កំណត់នូវវិធានទូទៅ ទីលំនៅវិជ្ជាជីវៈ និងកន្លែងពិគ្រោះយោបល់ ការផ្សព្វផ្សាយ មេធាវី និងអតិថិជន ទំនាក់ទំនងជាមួយភាគីម្ខាងទៀត និងសាក្សី ទំនាក់ទំនងជាមួយតុលាការ ទំនាក់ទំនងជាមួយសហភាតា និងសមាជិក នៃវិជ្ជាជីវៈប្រហាក់ប្រហែលគ្នា និងទំនាក់ទំនងជាមួយគណៈមេធាវី។

## ផ្នែកទី៤៖ លក្ខន្តិកៈមេធាវី និងនីតិវិធីចូលប្រកបវិជ្ជាជីវៈ

ដើម្បីក្លាយជាមេធាវី នឹងបានចូលប្រកបវិជ្ជាជីវៈមេធាវី គឺវាពិតជាមិនមែនជារឿងងាយស្រួលនោះទេ ដូចដែរយើងដឹងហើយថា មេធាវីមានកាតព្វកិច្ចប្រកាន់ខ្ជាប់នូវក្រមសីលធម៌ វិជ្ជាជីវៈ និងការទទួលខុសត្រូវចំពោះកូនក្តីរបស់ខ្លួន។មេធាវីគឺមិនត្រឹមតែជាអ្នកដែលយល់ដឹងស៊ីជម្រៅផ្នែកច្បាប់ប៉ុណ្ណោះទេតែមេធាវីក៏ជាអ្នកដែលមានចំណេះដឹងជ្រៅជ្រះទូលំទូលាយប្រកបដោយ ក្រមសីលធម៌វិជ្ជាជីវៈផងដែរ ហេតុដូចនេះហើយទើបមេធាវីគ្រប់រូបត្រូវតែទទួល ការបណ្តុះបណ្តាលឲ្យបានច្បាស់លាស់អំពីច្បាប់ស្តីពីលក្ខន្តិកៈមេធាវី បទបញ្ជាផ្ទៃក្នុង និងបច្ចេកទេសការពារក្តី ព្រមទាំងក្រមសីលធម៌មេធាវី ។ យោងតាមមាត្រា៣១ និង មាត្រា៣២នៃច្បាប់ស្តីពីលក្ខន្តិៈមេធាវី ដើម្បីចូលប្រកបវិជ្ជាជីវៈមេធាវីបាន គឺត្រូវបំពេញលក្ខខណ្ឌមួយចំនួន ដូចជា៖

- ត្រូវមានសញ្ជាតិជាខ្មែរ
- ត្រូវមានវិញ្ញាបនបត្រច្បាប់ ឬ សញ្ញាបត្រច្បាប់ដែលបានប្រកាសថាមានតម្លៃសមមូល។
- ត្រូវមានវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី។ វិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវីនេះត្រូវចេញដោយមជ្ឈមណ្ឌល បណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។ ការរៀបចំនិងការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលនេះ ត្រូវកំណត់ដោយអនុក្រឹត។
- មិនដែលត្រូវបានផ្តន្ទាទោសជាបទមជ្ឈិម ឬឧក្រិដ្ឋ ឬផ្តន្ទាទោសជាបទវិន័យ ឬ ផ្តន្ទាទោសជារដ្ឋបាលដូចជាការលុបឈ្មោះចោល ការបញ្ឈប់ពីមុខងារ ការហូតងារអំពីអំពើផ្ទុយនឹងកិត្តិយសឬអំពើមិនស្អាតស្អំ។
- មិនត្រូវមានធនក្ស័យផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ។[11]
- មិនចាំបាច់មានវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី និង បរិញ្ញាបត្រច្បាប់៖
    - ចៅក្រម ដែលបានបំរើការងារក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី ៥ ឆ្នាំ និងអតីតចៅក្រមដែលមានសញ្ញាបត្រមធ្យមសិក្សាច្បាប់ហើយដែលបានបំរើក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី២ ឆ្នាំ។
- មិនចាំបាច់មានវិញ្ញាបនបត្រខាងវិជ្ជាជីវៈមេធាវី៖
    - អ្នកមានបរិញ្ញាបត្រច្បាប់ ហើយ បានបំរើការងារក្នុងវិស័យច្បាប់ឬតុលាការលើសពី២ឆ្នាំ
    - មេធាវីដែលមានសញ្ជាតិដើមខ្មែរដែលចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៅប្រទេសក្រៅ
    - អ្នកមានសញ្ញាបត្របណ្ឌិតច្បាប់។[12]

[11] មាត្រា៣១ នៃច្បាប់ស្តីពី លក្ខន្តិកៈមេធាវី

តាមរយៈ លក្ខខណ្ឌដែលមានចែងក្នុងមាត្រាទាំងពីរខាងលើនេះយើងឃើញថា គេអាចចូលប្រកបវិជ្ជាជីវៈមេធាវីបានតាមរយៈពីរមធ្យោបាយ។ មធ្យោបាយទីមួយគឺ តាមរយៈការប្រឡងចូលមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ដើម្បីទទួលបានវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវី និងមធ្យោបាយទីពីរគឺតាមរយៈការស្នើសុំដោយត្រូវគោរពទៅតាមលក្ខខណ្ឌមួយចំនួន។

### ៤.១. តាមរយៈការប្រឡង

ជនដែលអាចចូលប្រកបវិជ្ជាជីវៈមេធាវីបាន គឺត្រូវមានវិញ្ញាបនបត្រសម្បទាខាងវិជ្ជាជីវៈមេធាវីដែលវិញ្ញាបនបត្រនេះត្រូវចេញដោយមជ្ឈមណ្ឌល បណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី[13]។ ហើយដើម្បីទទួលបានវិញ្ញាបនបត្រនេះគឺត្រូវតែឆ្លងកាត់ការប្រឡងចូលមជ្ឈមណ្ឌល និងទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។

#### ៤.១.១. លក្ខខ័ណ្ឌ

ដើម្បីអាចប្រឡងចូល ជាសិស្សមេធាវី និង ទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីនៅមជ្ឈមណ្ឌល បណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី បេក្ខជនត្រូវបំពេញលក្ខខ័ណ្ឌមួយចំនួនដូចជា៖

- បេក្ខជនទាំងពីរភេទត្រូវមានសញ្ជាតិខ្មែរ
- ត្រូវមានបរិញ្ញាប័ត្រច្បាប់ ឬ សញ្ញាប័ត្រច្បាប់ ដែលបានប្រកាសថាមានតម្លៃសមមូល
- មិនដែលត្រូវបានផ្តន្ទាទោសជាបទមជ្ឈិម ឬឧក្រិដ្ឋ ឬផ្តន្ទាទោសជាបទវិន័យ ឬ ផ្តន្ទាទោសជារដ្ឋបាលដូចជាការលុបឈ្មោះចោល ការបញ្ឈប់ពីមុខងារ ការហូតងារអំពីអំពើផ្ទុយនឹងកិត្តិយសឬអំពើមិនស្អាតស្អំ។ហើយមិនត្រូវមានធនក្ស័យផ្ទាល់ខ្លួនប្រកាសដោយតុលាការ។
- ត្រូវមានសីលធម៌ និង កាយសម្បទាគ្រប់គ្រាន់។[14]

#### ៤.១.២. ការប្រឡង

ចំពោះ ការកំណត់ចំនួនសិស្សមេធាវី នីតិវិធីនៃការប្រឡងជ្រើសរើសសិស្សមេធាវី កម្មវិធីបណ្តុះបណ្តាល គ្រូបណ្តុះបណ្តាល និង ការប្រឡងយកវិញ្ញាបនប័ត្រសម្បទាវិជ្ជាជីវៈមេធាវី ត្រូវពិនិត្យនិងសម្រេចដោយក្រុមប្រឹក្សាគណៈមេធាវី[15]។ ការប្រឡងនេះគឺមានពីរប្រភេទវិញ្ញាសារ គឺវិញ្ញាសារសរសេរ(ប្រឡងលើទី១)និងវិញ្ញាសារផ្ទាល់មាត់ (ចំពោះបេក្ខជនដែលបានប្រឡងជាប់លើវិញ្ញាសារសរសេររួច)។ បន្ទាប់ពីបានប្រឡងជាប់លើវិញ្ញាសារផ្ទាល់មាត់ហើយនោះគឺមានន័យថាគេបានជាប់

[12] មាត្រា៣២ នៃច្បាប់ស្តីពី លក្ខន្តិកៈមេធាវី

[13] មាត្រា៣១ វាក្យខ័ណ្ឌទី៣ នៃច្បាប់ស្តីពី លក្ខន្តិកៈមេធាវី

[14] មាត្រា៧ នៃអនុក្រឹតស្តីពី ការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី

[15] មាត្រា៦ នៃអនុក្រឹតស្តីពី ការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី

ដោយជោគជ័យ ហើយ បេក្ខជនត្រូវត្រៀមខ្លួនសម្រាប់ការចូលរៀននិង ទទួលការបណ្តុះ បណ្តាល នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។

#### ៤.១.៣. ការចុះកម្មសិក្សា

នៅពេលដែលបានបញ្ចប់វគ្គសិក្សានៅមជ្ឈមណ្ឌលដោយជោគជ័យរួច ក្រុមប្រឹក្សាគណៈមេធាវីនឹងធ្វើការពិនិត្យមើល លើរាល់លក្ខខណ្ឌដែលបេក្ខជនត្រូវបំពេញ និងធ្វើការសម្រេចចំពោះការអនុញ្ញាតឲ្យចូលប្រកបវិជ្ជាជីវៈ ក្រោយពីមានយោបល់ពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ បន្ទាប់មក មេធាវីដែលត្រូវបានទទួលឱ្យប្រកបវិជ្ជាជីវៈ ត្រូវធ្វើសច្ចាប្រណិធានជាមុននៅចំពោះមុខសាលាឧទ្ធរណ៍ ដោយមានវត្តមានប្រធានគណៈមេធាវីផង។ បន្ទាប់មកទៀត មេធាវីដែលទើបតែបានចុះឈ្មោះនោះ ត្រូវធ្វើកម្មសិក្សារយៈពេល១ឆ្នាំ ដែលក្នុងរយៈពេលមួយឆ្នាំនោះ មេធាវីនោះត្រូវទទួលការបំពាក់បំប៉នបន្ថែម ដែលរៀបចំឡើងដោយគណៈមេធាវី និងត្រូវចូលរួមបំរើការងារនៅក្នុងការិយាល័យមេធាវីណាមួយ ហើយនៅក្រោមការ ពិនិត្យរបស់មេធាវីម្នាក់ដែលក្រុមប្រឹក្សាគណៈមេធាវីចាត់តាំងឱ្យទទួលខុសត្រូវលើកម្មសិក្សានោះ។

### ៤.២. តាមការស្នើសុំ

#### ៤.២.១. លក្ខខ័ណ្ឌ

ការស្នើសុំប្រកបវិជ្ជាជីវៈមេធាវីគឺមិនចាំបាច់មានវិញ្ញាបនបត្រវិជ្ជាជីវៈមេធាវី និង បរិញ្ញាបត្រច្បាប់ទេ តែត្រូវបំពេញទៅតាមលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

- ករណីគ្មានវិញ្ញាបនបត្រវិជ្ជាជីវៈមេធាវី និង បរិញ្ញាប័ត្រច្បាប់
    - ចៅក្រមដែលបានបំរើការងារក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី ៥ ឆ្នាំ
    - និង អតីតចៅក្រម ដែលមានសញ្ញាបត្រមធ្យមសិក្សាច្បាប់ហើយ ដែលបានបំរើក្នុងវិជ្ជាជីវៈរបស់ខ្លួនលើសពី ២ ឆ្នាំ។[16]
- ករណីគ្មានវិញ្ញាបនបត្រខាងវិជ្ជាជីវៈមេធាវី៖
    - អ្នកមានបរិញ្ញាបត្រច្បាប់ ហើយ បានបំរើការងារក្នុងវិស័យច្បាប់ឬតុលាការលើសពី២ឆ្នាំ
    - មេធាវីដែលមានសញ្ជាតិដើមខ្មែរដែលចុះឈ្មោះក្នុងបញ្ជីគណៈមេធាវីនៅប្រទេសក្រៅ
    - អ្នកមានសញ្ញាបត្របណ្ឌិតច្បាប់។[17]

#### ៤.២.២. ការដាក់ពាក្យសុំ

[16] មាត្រា៣២ នៃច្បាប់ស្តីពី លក្ខន្តិកៈមេធាវី

[17] មាត្រា៣២ វាក្យខណ្ឌ២ នៃច្បាប់ស្តីពី លក្ខន្តិកៈមេធាវី

បុគ្គលណាដែលមានបំណងចង់ស្នើសុំប្រកបវិជ្ជាជីវៈមេធាវី ហើយដែលបានបំពេញតាមលក្ខខណ្ឌនៃមាត្រា ៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី គឺគេត្រូវទៅទាក់ទងខាងការិយាល័យរដ្ឋបាលនៃគណៈមេធាវី នៅរាល់ពេលដែលធ្វើការ។ ហើយចំពោះការដាក់ពាក់សុំនេះគឺតម្រូវឲ្យបង់ថ្លៃលើពាក្យសុំនេះ ដែលការកំណត់ទម្រង់ពាក្យសុំនិងតម្លៃនៃពាក្យនេះគឺកំណត់ដោយគណៈមេធាវី[18] ។នៅក្រោយពេលដែលបំពេញពាក្យសុំរួចរាល់គេត្រូវយកពាក្យសុំនោះទៅដាក់នៅការិយាល័យរដ្ឋបាលគណៈមេធាវី ដោយភ្ជាប់ជាមួយឯសារមួយចំនួនដូចជា៖

- ពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា៣២
- ប្រវត្តិរូបសង្ខេបសាមីខ្លួន
- លិខិតថ្កោលទោសដែលនៅមានសុពលភាព
- ឯកសារតម្រូវផ្សេងៗទៀត ដែលកំណត់ដោយគណៈមេធាវី។

### ៤.២.៣. ការដាក់ពាក្យធ្វើកម្មសិក្សា

បន្ទាប់ពីគណៈមេធាវីបានពិនិត្យ និង បញ្ជូនឯកសារពាក្យសុំនោះទៅក្រុមអធិការកិច្ច ក្រុមអធិការកិច្ចត្រូវបំពេញតួនាទីរបស់ខ្លួនក្នុងរយៈពេលយូរបំផុត ៣០ថ្ងៃ ហើយត្រូវធ្វើរបាយការណ៍អធិការកិច្ច និង បញ្ជូនរបាយការណ៍នោះទៅកាន់ប្រធាននាយកដ្ឋានអធិការកិច្ចដើម្បីត្រួតពិនិត្យ និង វាយតម្លៃ មុននឹងបញ្ជូនទៅប្រធានគណៈមេធាវី។ បើរបាយការណ៍នោះត្រឹមត្រូវ និងមិនមានខ្វះចន្លោះចំណុចអ្វីទេនោះ ប្រធានគណៈមេធាវីត្រូវកំណត់ពេលដើម្បីធ្វើការសំភាសន៍បេក្ខជនផ្ទាល់ក្នុង រយៈពេល ៣០ ថ្ងៃ[19]។ នៅពេលដែលការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវីបានបោះឆ្នោតសម្រេចយល់ព្រមចំពោះសំណើនោះដោយមានសម្លេងគាំទ្រភាគច្រើន គឺមានន័យថាបេក្ខជននោះគឺទទួលបានការអនុញ្ញាតឲ្យចូលប្រកបវិជ្ជាជីវៈមេធាវីហើយ។ បន្ទាប់ពីបេក្ខជន ធ្វើសច្ចាប្រណិធានចំពោះមុខសាលាឧទ្ធរណ៍រួច បេក្ខជននោះត្រូវដាក់ពាក្យសុំធ្វើកម្មសិក្សានិងចុះធ្វើកម្មសិក្សារយៈពេល ១២ខែ និងធ្វើរបាយការណ៍បញ្ចប់ការសិក្សាដាក់ឲ្យគណៈមេធាវីពិនិត្យ និង សម្រេចពីការអនុញ្ញាត ឬ មិនអនុញ្ញាតឲ្យក្លាយជាមេធាវីពេញសិទ្ធិ។

## ផ្នែកទី៥៖ ក្រមសីលធម៌វិជ្ជាជីវៈមេធាវី (ការប្រកបវិជ្ជាជីវៈ)

ក្នុងការប្រកបវិជ្ជាជីវៈមេធាវី មេធាវីត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌មេធាវី ជាពិសេសគោរពតាមគោលការណ៍នីមួយៗតាមការអនុញ្ញាតរបស់ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

[18] ប្រការ៦នៃសេចក្តីសម្រេចពីនីតិវិធីនៃការទទួលពិនិត្យនិងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា៣២
[19] ប្រការ១៤នៃសេចក្តីសម្រេចពីនីតិវិធីការទទួលពិនិត្យនិងសម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវីតាមមាត្រា៣២

### ៥.១. ឯករាជ្យភាព និងសេរីភាព នៃវិជ្ជាជីវៈមេធាវី

វិជ្ជាជីវៈមេធាវី ជាវិជ្ជាជីវៈឯករាជ្យ និងសេរីដែលចូលរួមបម្រើវិស័យយុត្តិធម៌ និងប្រព្រឹត្តទៅបានតែក្នុងក្របខ័ណ្ឌនៃគណៈមេធាវីប៉ុណ្ណោះ។[20] វិជ្ជាជីវៈមេធាវីស្ថិតនៅក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់គណៈមេធាវីដែលជាស្ថាប័នឯករាជ្យពីគណៈបក្សនយោបាយ អង្គការសាសនាឬអង្គការនានាផ្សេងទៀត។ [21] ឯក្សរាជ្យភាពនៃវិជ្ជាជីវៈមេធាវីមានន័យថា នៅពេលអនុវត្តវិជ្ជាជីវៈរបស់ខ្លួនមេធាវីម្នាក់ៗមិនស្ថិតនៅក្រោមបញ្ជា ឬការណែនាំពីបុគ្គលណាម្នាក់ ឬពីស្ថាប័នណាមួយឡើយ។ នៅក្នុងការផ្តល់សេវាកម្មច្បាប់ មេធាវីគ្រប់រូបត្រូវធ្វើឡើងដោយគោរពតាមច្បាប់ បទប្បញ្ញត្តិជាធរមាន និងវិធានវិជ្ជាជីវៈ ហើយបំពេញការងារតាមបច្ចេកទេសជំនាញរបស់ខ្លួន ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់អតិថិជន ដោយមិនចំណុះនិងស្ថិតនៅក្រោមការជ្រៀតជ្រែករបស់ស្ថាប័ន ឬបុគ្គលណាមួយឡើយ។ មេធាវីអនុវត្តវិជ្ជាជីវៈដោយផ្អែកទៅលើ ជំនាញវិជ្ជាជីវៈរៀងៗខ្លួនយោងទៅតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និងក្រមសីលធម៌មេធាវីដោយមិនអនុវត្តវិជ្ជាជីវៈទៅតាមការណែនាំឬឥទ្ធិពលណាមួយឡើយ។ រីឯសេរីភាពនៃវិជ្ជាជីវៈមេធាវីគឺមានន័យថា មេធាវីមានសេរីភាពពេញលេញក្នុងការជ្រើសរើសទីកន្លែងប្រកបវិជ្ជាជីវៈ សេរីភាពទទួល ឬមិនទទួលផ្តល់សេវាកម្មច្បាប់ជូនអតិថិជន សេរីភាពក្នុងការកំណត់កំរៃសេវា និងសេរីភាពក្នុងការជ្រើសរើសមធ្យោបាយបំពេញការងារជាដើម។ កំរៃសេវារបស់មេធាវី គឺអាស្រ័យតាមការ ព្រមព្រៀងរវាងមេធាវី និងអតិថិជន ពោលគឺមិនមានច្បាប់ ឬបទដ្ឋានគតិយុត្តណាមួយកំណត់ពីអត្រានៃកម្រៃសេវារបស់មេធាវីទេ។ មេធាវីមានតួនាទីការពារសិទ្ធិ សេរីភាពរបស់បុគ្គល និងជួយពង្រឹងយុត្តិធម៌សង្គម។ មេធាវីជាជំនួយការយុត្តិធម៌របស់សង្គម តែមិនមែនជាជំនួយការឱ្យតុលាការ។ នៅក្នុងករណីមេធាវីប្រព្រឹត្តបំពាននឹងវិធានវិជ្ជាជិវៈ មេធាវីនឹងត្រូវទទួលទណ្ឌកម្មពីក្រុមប្រឹក្សាគណៈមេធាវី។

### ៥.២. តម្លៃសីលធម៌នៃវិជ្ជាជីវៈមេធាវី

#### ៥.២.១. សញ្ញាណទូទៅ

នៅគ្រប់កាលៈទេសៈមេធាវីត្រូវគោរពពាក្យសម្បថនិងត្រូវគោរពគោលការណ៍នៃសម្បជញ្ញៈមនុស្សធម៌ និងសេចក្តីថ្លៃថ្នូរនៃវិជ្ជាជីវៈ។ មេធាវីត្រូវអនុវត្តវិជ្ជាជីវៈរបស់ខ្លួនប្រកបដោយសេចក្តីថ្លៃថ្នូរដោយសតិសម្បជញ្ញៈ សេចក្តីទៀងត្រង់ មនុស្សធម៌ ស្មារតីឯករាជ្យនិងដោយគោរពតាមរដ្ឋធម្មនុញ្ញនិងច្បាប់ទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា។ មេធាវីមិនត្រូវចូលរួមសកម្មភាពណា ដែលមាន

[20] មាត្រា១ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

[21] មាត្រា១៣ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

លក្ខណៈផ្ទុយច្បាប់ វិធានវិជ្ជាជីវៈ និងសម្បជញ្ញៈរបស់ខ្លួនឡើយ។ មេធាវីត្រូវគោរពនិងប្រតិបត្តិនូវគោលការណ៍សុចរិតភាព និងភាពស្មោះត្រង់។[22] មេធាវីមានបេសកកម្មចូលរួមក្នុងការរៀបចំនីតិរដ្ឋ ជួយពង្រឹងយុត្តិធម៌សង្គម និងការពារសិទ្ធិមនុស្ស។[23]

### ៥.២.២. ការទទួលរឿងក្តី

មេធាវីមានសិទ្ធិទទួល ឬមិនទទួលជួយអតិថិជន លើកលែងតែត្រូវចាត់តាំងដោយប្រធានគណៈមេធាវី។ មេធាវីអាចទទួលរឿងក្តីតាមរយៈកូនក្តីផ្ទាល់ ឬតតិយដោយប្រធានគណៈមេធាវី។ ប្រសិនបើយល់ព្រមទទួលយកបេសកកម្ម មេធាវីត្រូវបំពេញ បេសកកម្មនោះដោយយកចិត្តទុកដាក់រហូតដល់ចប់បេសកកម្ម លើកលែងអតិថិជនឈប់ពឹងពាក់។ មេធាវីត្រូវពន្យល់ ប្រាប់អតិថិជនរបស់ខ្លួនអំពីលក្ខខណ្ឌនៃរឿងក្តី ជម្រើសនៃវិធីដោះស្រាយ កម្រៃសេវាមេធាវីការចំណាយ និងកម្រៃផ្សេងៗទៀត ដោយផ្អែកលើពត៌មានដែលទទួលបានពីអតិថិជន។ នៅក្នុងការបំពេញបេសកកម្មរបស់ខ្លួនមេធាវី ត្រូវស្ថិតនៅជាម្ចាស់មធ្យោបាយការពារ ហើយមេធាវីមិនត្រូវផ្តល់ការធានាចំពោះអតិថិជនទាក់ទងនឹងលទ្ធផលវិជ្ជមាននៃរឿងក្តីឡើយ។[24] មេធាវីទទួលការពារ និងតំណាងរឿងក្តីទៅតាមការពឹងពាក់ពីអតិថិជន។ នៅក្នុងការងារការពារក្តីជូនជនក្រីក្រ មេធាវីទទួលការពារក្តីតាមការចាត់តាំងរបស់ប្រធានគណៈមេធាវី។ មេធាវីទាំងអស់មានកាតព្វកិច្ចជួយការពារក្តីជូនជនក្រីក្រតាមការចាត់តាំងរបស់ប្រធានគណៈមេធាវី ហើយត្រូវ យកចិត្តទុកដាក់ការពារក្តីឱ្យដូចជាការពារឱ្យអតិថិជន ដែលមកពឹងពាក់ខ្លួនដែរ។[25]

### ៥.២.៣. ការប្រុងប្រយ័ត្ន

ករណីដែលមេធាវីព្រមទទួលរឿងក្តីរបស់អតិថិជន មេធាវីត្រូវគិតពីផលប្រយោជន៍របស់អតិថិជនឱ្យដូចជាផលប្រយោជន៍ខ្លួនដែរ។ ដូចនេះ មេធាវីត្រូវប្រើប្រាស់នូវសមត្ថភាព និងជំនាញវិជ្ជាជីវៈដែលខ្លួនមានទាំងអស់ដើម្បីបំពេញកិច្ចការដែលអតិថិជនបានពឹងពាក់ប្រកបដោយការប្រុងប្រយ័ត្ន។ ក្នុងករណីដែលមានការធ្វេសប្រហែស អតិថិជនអាចប្តឹងមេធាវីចំពោះការខូចខាត។ ឧទាហរណ៍ថា អតិថិជនបានពឹងពាក់មេធាវីឱ្យរៀបចំធ្វើបណ្តឹងឧទ្ធរណ៍នឹងសាលក្រមរបស់សាលា

[22] មាត្រា៣៨ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និងមាត្រា៣ និង៦ នៃក្រមសីលធម៌មេធាវី ឆ្នាំ២០១២

[23] មាត្រា៩ នៃក្រមសីលធម៌មេធាវី ឆ្នាំ២០១២

[24] មាត្រា២២ នៃក្រមសីលធម៌មេធាវី ឆ្នាំ២០១២

[25] មាត្រា ២៩ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

ដំបូងដែលខ្លួនមិនសុខចិត្ត ហើយ មេធាវីមានការធ្វេសប្រហែសដោយខកខានមិនបានរៀបចំប្តឹងឧទ្ធរណ៍នឹងសាលក្រមរបស់សាលក្រមរបស់សាលាដំបូងខាងលើ នៅក្នុងកំឡុងពេលដែលច្បាប់កំណត់ បណ្តាលឱ្យអតិថិជនជនទទួលរងនូវការខូចខាតផលប្រយោជន៍ស្របច្បាប់របស់ខ្លួននោះ មេធាវីត្រូវទទួលខុសត្រូវសងការខូចខាត។ អាស្រ័យហេតុនេះ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីតម្រូវឱ្យមេធាវីបង់ប្រាក់ធានារ៉ាប់រងសម្រាប់ធានារ៉ាប់រងការទទួលខុសត្រូវរបស់ខ្លួនក្នុងវិជ្ជាជីវៈ ដើម្បីធានាការការពារផលប្រយោជន៍របស់អតិថិជន។[26]

## ៥.២.៤. សុចរិតភាព និងភាពស្មោះត្រង់

មេធាវីត្រូវកសាងជំនឿទុកចិត្តរបស់អតិថិជន។ ជាការពិតណាស់ មេធាវីមិនអាចផ្តល់ការធានាចំពោះអតិថិជនទាក់ទងនឹងលទ្ធផលវិជ្ជមាននៃរឿងក្តីឡើយ ប៉ុន្តែមេធាវីត្រូវខិតខំប្រឹងប្រែងបំពេញបេសកកម្មរបស់ខ្លួនឱ្យអស់ពីសមត្ថភាព។ ប្រសិនមេធាវីចង់បញ្ចប់បេសកកម្មរបស់ខ្លួនមុនពេលកំណត់ មេធាវីរូបនោះត្រូវជូនដំណឹងទៅអតិថិជនរបស់ខ្លួនអំពីការបញ្ឈប់ ឬការដកខ្លួនពីការបំពេញការងារ នេះនៅក្នុងពេលវេលាមួយសមស្របដែលផ្តល់លទ្ធភាពឱ្យអតិថិជនអាចបង្ការផលប្រយោជន៍របស់ខ្លួននិងស្វែងរកមេធាវីផ្សេងទៀតមក ដើម្បីឱ្យជួយការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួន។ [27] មេធាវីមិនត្រូវប្រើឧបាយកលដើម្បីទាញយកផលប្រយោជន៍ក្នុងស្ថានភាពដែលអតិថិជនមិនមានចំណេះដឹងផ្នែកច្បាប់ឡើយ។មេធាវីត្រូវគោរពនិងប្រតិបត្តិនូវគោលការណ៍សុចរិតនិងភាពស្មោះត្រង់។[28]

## ៥.២.៥. ការរក្សាការសម្ងាត់នៃវិជ្ជាជីវៈ

មេធាវីត្រូវដឹងកាតព្វកិច្ចរបស់ខ្លួនក្នុងការរក្សាការសម្ងាត់វិជ្ជាជីវៈ [29] ដោយហេតុថាការបំពានវិធានដែលពាក់ព័ន្ធនឹងការសម្ងាត់វិជ្ជាជីវៈអាចឱ្យមេធាវីទទួលនូវទណ្ឌកម្មជាបទវិន័យ និងផ្តន្ទាទោសព្រហ្មទណ្ឌ។[30]

---

[26] មាត្រា ៧៣ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

[27] មាត្រា ២៩ នៃក្រមសីលធម៌មេធាវីឆ្នាំ២០១២

[28] មាត្រា ៦ នៃក្រមសីលធម៌មេធាវីឆ្នាំ២០១២

[29] មាត្រា ៥៨ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និងមាត្រា៧ នៃក្រមសីលធម៌មេធាវីឆ្នាំ២០១២

[30] មាត្រា ៧៨ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និងមាត្រា ៣១៤ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

មេធាវីមិនអាចបំពារបំពានលើការសម្ងាត់នៃវិជ្ជាជីវៈបានឡើយ ហើយក៏មិនអាចត្រូវបានបង្ខំឱ្យបំពារបំពានលើការសម្ងាត់វិជ្ជាជីវៈរបស់ខ្លួន ទោះបីនៅមុខតុលាការក៏ដោយ។ ការសម្ងាត់នេះមិនត្រូវអាចឱ្យជនណាម្នាក់ស្រង់យកបានឡើយ ទោះបីជាអតិថិជនក៏ដោយ។ឧទាហរណ៍៖ មេធាវីមិនអាចនិយាយអង្គហេតុនៃរឿងក្តីរបស់អតិថិជន ខ្លួនប្រាប់ទៅមិត្តភក្តិ គ្រួសារ ប្រព័ន្ធផ្សព្វផ្សាយ ឬជនណាម្នាក់ឡើយ។ ត្រូវចាត់ទុកជាការសម្ងាត់នៃវិជ្ជាជីវៈ ការពិគ្រោះយោបល់ ការផ្តល់យោបល់ ឯកសារក្រៅផ្លូវការទាំងឡាយដែលមេធាវីតាក់តែងឡើង សម្រាប់អតិថិជនរបស់ខ្លួន លិខិតស្នាមទាំងឡាយដែលមេធាវីនិងអតិថិជនរបស់ខ្លួនផ្ញើទាក់ទងគ្នា។ ការរក្សាសម្ងាត់វិជ្ជាជីវៈជួយការពារដល់ផលប្រយោជន៍ កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់អតិថិជនផងដែរ។ កាតព្វកិច្ចរបស់មេធាវី ក្នុងការរក្សាការសម្ងាត់វិជ្ជាជីវៈ គឺជាកាតព្វកិច្ចក្នុងចំណោមកាតព្វកិច្ចដទៃទៀតដែលចងភ្ជាប់ ទៅនឹងកាតព្វកិច្ចមានភាពស្មោះត្រង់ជាមួយអតិថិជន។ ក្រៅពីនេះ ការបំពេញកាតព្វកិច្ចទាំងនេះ បានជួយដល់ការកសាងទំនុកចិត្តរបស់អតិថិជន មកលើមេធាវី និងជួយសម្រួលដល់ការទាក់ទងគ្នាដ៏ល្អរវាងអតិថិជន និងមេធាវីរបស់ខ្លួន។ មេធាវីមិនមានកាតព្វកិច្ចរក្សាការសម្ងាត់ទេ ក្នុងករណីដែលមេធាវីត្រូវធ្វើការឆ្លើយតបទៅនឹងបណ្តឹងអតិថិជនរបស់ខ្លួន ប៉ុន្តែត្រូវស្ថិតត្រឹមក្នុងកម្រិតនៃការចាំបាច់នៃការការពារខ្លួនតែប៉ុណ្ណោះ។

### ៥.២.៦. ទំនាស់ផលប្រយោជន៍ និងការហាមឃាត់

ក្នុងគោលបំណងការពារផលប្រយោជន៍ស្របច្បាប់របស់អតិថិជនមេធាវីត្រូវហាមឃាត់ក្នុងការ ធ្វើជាមេធាវីការពារ ឬតំណាងឱ្យអតិថិជនក្នុងករណីដូចខាងក្រោមៈ

- រឿងក្តីមួយដែលមេធាវីខ្លួនឯង ឬក្រុមមេធាវីរបស់ខ្លួន បានជួយបដិភាគីនៅក្នុងការផ្តល់យោបល់ ឬទទួលយល់ព្រមតំណាងឱ្យបដិភាគីរួចហើយ
- នៅពេលដែលផលប្រយោជន៍របស់អតិថិជនម្នាក់មានទំនាស់ជាមួយផលប្រយោជន៍របស់អតិថិជនម្នាក់ទៀតនៅក្នុងរឿងក្តីដែលមេធាវី ឬក្រុមមេធាវីរបស់ខ្លួនកំពុងកាន់
- នៅពេលដែលអតិថិជនទាំងពីរជាភាគីជាវិវាទនៅក្នុងរឿងក្តីតែមួយ
- នៅពេលដែលអតិថិជនម្នាក់ចង់ពឹងពាក់មេធាវី ឬក្រុមមេធាវីរបស់ខ្លួនតែមេធាវីឬក្រុមមេធាវីនេះធ្លាប់បានទទួលជួយបដិភាគីក្នុងរឿងដទៃ ឬមេធាវីបានយល់ព្រមផ្តល់យោបល់ផ្នែកច្បាប់បន្តទៀត លើកលែងតែរឿងក្តីចុងក្រោយ ដែលមេធាវី ឬក្រុមមេធាវីដែលធ្លាប់ពាក់ព័ន្ធនោះបានកន្លងផុតទៅអស់រយៈពេល ២ ឆ្នាំ។

- រឿងក្តីមួយដែលមេធាវីឬក្រុមមេធាវីរបស់ខ្លួនបានដើរតួជា អាជ្ញាកណ្តាលអ្នកផ្សះផ្សា ឬ សម្របសម្រួលក្នុងទម្រង់នីតិវិធីនៃការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ។ក្នុងករណីដែលមេធាវី ឬ ក្រុមមេធាវីជាទីប្រឹក្សាឬធ្លាប់ជាទីប្រឹក្សារបស់អតិថិជនច្រើនគ្នានៅមេធាវីនឹងអាចទទួលការពារ ផលប្រយោជន៍ភាគីណាមួយបានលុះត្រាតែត្រូវបានជម្រាបជូនដំណឹងទៅភាគីឯទៀត និងបន្ទាប់ពី ទទួលបានការយល់ព្រមជាមុន ហើយត្រូវប្រុងប្រយ័ត្នកុំឱ្យបាត់បង់នូវភាពថ្លៃថ្នូរ កិត្តិយស និងការ សម្ងាត់វិជ្ជាជីវៈ។[31]

ដើម្បីធានាបាននូវការការពារផលប្រយោជន៍ស្របច្បាប់របស់អតិថិជន ច្បាប់ស្តីពីលក្ខន្តិកៈ មេធាវីក៏បាន កំណត់ហាមឃាត់មិនឱ្យមេធាវី ដែលធ្លាប់ជាអតីតមន្ត្រីរាជការ ធ្វើបទអន្តរាគមន៍ ការពារកូនក្តីប្រឆាំងនឹងក្រសួង មន្ទីររដ្ឋបាល ដែលខ្លួនស្ថិតនៅក្រោមឱវាទពីមុនដែរ។ មេធាវីនោះ អាចធ្វើជាតំណាង ឬការពារកូនក្តីប្រឆាំងនឹងក្រសួង មន្ទីររដ្ឋបាល ដែលខ្លួនធ្លាប់ស្ថិតនៅក្រោមឱ វាទបាន លុះត្រាតែផុតរយៈពេល០៥ ឆ្នាំគិតពីថ្ងៃ ដែលឈប់ពីមុខងាររបស់ខ្លួន។[32]

### ៥.៣. ការបង់វិភាគទាន

គណៈមេធាវីមានឯករាជ្យភាពផ្នែករដ្ឋបាល និងស្វ័យភាពហិរញ្ញវត្ថុដាច់ដោយឡែកពីស្ថាប័ន រដ្ឋាភិបាលទាំងឡាយ។គណៈមេធាវីមិនចំណុះឱ្យអំណាចសាធារណៈ និងមិនប្រើប្រាស់ថវិកាជាតិ ដូចស្ថាប័នសាធារណៈដទៃទៀតឡើយ។ ផ្អែកតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និង ក្រមសីលធម៌ មេធាវី មេធាវីទាំងអស់ដែលបច្ចុប្បន្នកំពុងមានឈ្មោះក្នុងបញ្ជីគណៈមេធាវីមានកាតព្វកិច្ចបង់ភាគ ទានជូនគណៈមេធាវី។ គណៈមេធាវីប្រើប្រាស់ភាគទាននេះសម្រាប់ទ្រទ្រង់សកម្មភាព និងដំណើរ ការរដ្ឋបាលរបស់គណៈមេធាវី។ ភាគទាននេះត្រូវតែបង់ឱ្យបានទៀងទាត់ជាប្រចាំរាល់ត្រីមាសដោយ ត្រូវបង់នៅដំណាច់ ត្រីមាសនីមួយៗ។ មេធាវីម្នាក់ៗត្រូវបង់ភាគទានឱ្យបានទាន់ពេលវេលា ដែល បានកំណត់។ មេធាវីណាដែលមិនបានបង់ភាគទាន ត្រូវទទួលទណ្ឌកម្មហាមឃាត់មិនឱ្យប្រកប វិជ្ជាជីវៈមេធាវី។[33]

## ផ្នែកទី៦៖ សារៈសំខាន់ និង តួនាទីរបស់មេធាវី

### ៦.១. បេសកកម្មរបស់មេធាវី

---

[31] មាត្រា ២៥ នៃក្រមសីលធម៌មេធាវីឆ្នាំ២០១២

[32] មាត្រា ៥៥ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

[33] មាត្រា ៥៥ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី

មេធាវីជាតួអង្គមួយដែលចូលរួមបម្រើវិស័យយុត្តិធម៌ ពោលគឺមេធាវីមានបេសកកម្មចូលរួមក្នុងការរៀបចំនីតិរដ្ឋ ពង្រឹងយុត្តិធម៌សង្គម និងការពារសិទ្ធមនុស្ស។[34] មេធាវីជាជំនួយការយុត្តិធម៌របស់សង្គមដែលជម្រុញឱ្យមានយុត្តិធម៌ក្នុងដំណើរការនីតិវិធីរបស់ស្ថាប័នយុត្តាធិការ និងស្ថាប័នមានសមត្ថកិច្ច។ នៅក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌប្រភេទខ្លះ ដូចជារឿងក្តីនៃបទល្មើសឧក្រិដ្ឋ និងរឿងក្តីដែលមានអតិថិជនជាជនជាប់ចោទ ច្បាប់តម្រូវឱ្យមានមេធាវីជាចាំបាច់។

## ៦.២. តួនាទីរបស់មេធាវី

### ៦.២.១. សញ្ញាណទូទៅ

ដើម្បីចូលរួមក្នុងការរៀបចំនីតិរដ្ឋ តាមរយៈគណៈមេធាវី មេធាវីអាចចូលរួមក្នុងសកម្មភាពសង្គម ដូចជាផ្តល់ការអប់រំ និងលើកកម្ពស់ការយល់ដឹងផ្នែកច្បាប់ ព្រមទាំងបទប្បញ្ញត្តិនានាដែលបានអនុម័តដោយអង្គការនីតិប្បញ្ញត្តិ ឬ ចេញដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ទៅកាន់សាធារណជន។

មេធាវីមានតួនាទីក្នុងការពិគ្រោះយោបល់ ផ្តល់ប្រឹក្សា តំណាង ឬការពារកូនក្តីនៅគ្រប់សាលាជម្រះក្តី និងគ្រប់ដំណាក់កាលនៃនីតិវិធី រាប់បញ្ចូលទាំងរឿងរដ្ឋប្បវេណី ព្រហ្មទណ្ឌ ពាណិជ្ជកម្ម រដ្ឋបាល ការងារ និងសង្គមកិច្ច។[35] មេធាវីក៏អាចជួយការពារកូនក្តីនៅចំពោះមុខក្រុមប្រឹក្សាវិន័យបានផងដែរ។ មេធាវីផ្តល់យោបល់ និងរៀបចំតាក់តែងលិខិតស្នាមគតិយុត្តផ្សេងៗ ព្រមទាំងផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ដល់សាធារណជនទូទៅ។ មេធាវីអាចត្រូវបានចាត់តាំងដោយគូក្តី ឬចៅក្រមឱ្យបំពេញមុខងារជាអ្នកផ្សះផ្សា ឬជាអ្នកសម្រុះសម្រួល ឬអាជ្ញាកណ្តាលក្នុងករណីដែលច្បាប់អនុញ្ញាត[36]។ ដោយមានការពឹងពាក់ពីអតិថិជនមេធាវីក៏មានសិទ្ធិធ្វើជាតំណាងដោយអាណត្តិ និងការពារផលប្រយោជន៍ស្របច្បាប់ឱ្យអតិថិជន នៅចំពោះមុខស្ថាប័នមានសមត្ថកិច្ចនានាផ្សេងទៀតដែរ។

## ៦.៣. ការពិគ្រោះយោបល់ផ្នែកច្បាប់

ទំនាក់ទំនងជាចម្បងរវាងមេធាវី និងអតិថិជននៅក្នុងដំណាក់កាលដំបូង គឺអតិថិជនមកជួប

[34] មាត្រា១ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី និងមាត្រា៤ នៃក្រមសីលធម៌មេធាវីឆ្នាំ២០១២។

[35] មាត្រា២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

[36] មាត្រា៣ នៃច្បាបប់ស្តីពីលក្ខន្តិកៈមេធាវី។

មេធាវីដើម្បីពិគ្រោះយោបល់។ ដំណាក់កាលនេះមានសារៈសំខាន់ខ្លាំងណាស់សម្រាប់អតិថិជនក៏ដូចជាមេធាវី ដោយហេតុថាភាគីទាំងពីរអាចយល់ពីគ្នាទៅវិញទៅមកបានល្អ ជាពិសេស អតិថិជនអាចដឹងពីសមត្ថកិច្ចរបស់មេធាវី និងចាប់ផ្ដើមមានទំនុកចិត្តលើមេធាវី។មេធាវីគួរគប្បីកត់ត្រាចំណុចសំខាន់ពាក់ព័ន្ធអង្គហេតុ និងប្រសិនបើចាំបាច់ គួរសាកសួរបន្ថែមឱ្យកាន់តែច្បាស់។ ជាដំបូន្មានមេធាវីគួរស្នើអតិថិជនដែលមកពិគ្រោះយោបល់ឱ្យប្រាប់ពីហេតុការណ៍ដែលបានកើតឡើងឱ្យបានច្បាស់លាស់ និងពិតប្រាកដ និងយកមកជាមួយនូវឯកសារដែលចាំបាច់។

### ៦.៤. ការផ្ដល់ប្រឹក្សាផ្នែកច្បាប់

មេធាវីត្រូវតែយល់ឱ្យច្បាស់ពីអង្គហេតុ និងច្បាប់នានាដែលពាក់ព័ន្ធនឹងរឿងក្ដីមុននឹងធ្វើការផ្ដល់ប្រឹក្សាច្បាប់។ ដើម្បីយល់ឱ្យបានច្បាស់នូវអង្គហេតុមេធាវីគប្បីជម្រុញឱ្យអតិថិជនរៀបរាប់ហេតុការណ៍ឱ្យបានលម្អិតដែលពាក់ព័ន្ធនឹងអង្គហេតុ។ មេធាវីត្រូវកត់ត្រារាល់ចំណុចសំខាន់ទាំងអស់ដែលពាក់ព័ន្ធនឹងអង្គហេតុ ជាពិសេស អង្គហេតុចម្បង របស់រឿងក្ដីនីមួយៗ។ បន្ទាប់ពីបានធ្វើការវិភាគលើអង្គហេតុ មេធាវី ត្រូវកំណត់ថាច្បាប់ណាខ្លះដែលគួរលើកយកមកអនុវត្ត និងថាតើមានបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតដែរឬទេ ដើម្បីឱ្យមេធាវីអាចផ្ដល់ប្រឹក្សាច្បាប់ដ៏ត្រឹមត្រូវទៅកាន់អតិថិជនរបស់ខ្លួន។ ដោយសារការអនុវត្តមានកើតឡើងនូវបញ្ហាមួយចំនួន ជាដំបូន្មានមេធាវីគួរផ្ដល់ប្រឹក្សាឱ្យអតិថិជន ទាំងទិដ្ឋភាពច្បាប់ និងជម្រាបជូនផងដែរនូវទិដ្ឋភាពនៃការអនុវត្ត។ ទោះជាយ៉ាងណាក៏ដោយ អតិថិជនមានសិទ្ធិក្នុងការសម្រេចចំពោះសកម្មភាពដែលនឹងត្រូវធ្វើពេលក្រោយទៀតដោយផ្អែកលើការផ្ដល់ប្រឹក្សារបស់មេធាវី។

# ជំពូកទី ២
# តួនាទីមេធាវីក្នុងនីតិវិធីរឿងក្តីរដ្ឋប្បវេណី
# នៅសាលាដំបូង

# ជំពូកទី ២
# តួនាទីមេធាវីក្នុងនីតិវិធីរឿងក្តីរដ្ឋប្បវេណីនៅសាលាដំបូង

បណ្តឹង គឺជាសកម្មភាពទាមទារដែលដើមចោទបានប្តឹងចំពោះចុងចម្លើយទៅតុលាការនៃការជំនុំជម្រះលើកទី១ ដោយសុំឲ្យតុលាការពិចារណា និង ចេញសាលក្រមទៅតាមអត្ថន័យត្រង់ចំណុចកម្មវត្ថុនៃពាក្យបណ្តឹងរបស់ខ្លួន[37]។ យោងតាមមាត្រា២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ បណ្តឹងរដ្ឋប្បវេណីមានគោលបំណង អោយតុលាការដោះស្រាយវិវាទរដ្ឋប្បវេណី ដោយផ្អែកលើច្បាប់ ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន ។ បណ្តឹងអាចធ្វើឡើងបាន ក្នុងករណីដែលបណ្តឹងនោះមានកម្មវត្ថុជាវិវាទតាមផ្លូវច្បាប់ជាក់ស្តែង និង ដែលវិវាទនោះអាចដោះស្រាយបានដោយសាលក្រម[៣៨]។ ការទាមទារតាមផ្លូវបណ្តឹងមានបីប្រភេទទៅតាមខ្លឹមសារនៃបណ្តឹងដូចជា៖ បណ្តឹងទាមទារឲ្យផ្តល់តាវកាលិក បណ្តឹងទាមទារឲ្យបញ្ជាក់ពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិនិងបណ្តឹងទាមទារឲ្យបង្កើត ឬ រំលត់ទំនាក់ទំនងគតិយុត្តិ[៣៩]។ នៅពេលដែលមានវិវាទរដ្ឋប្បវេណីកើតឡើង ហើយគូភាគីនៃជម្លោះទាំងនោះត្រូវការជំនួយផ្នែកច្បាប់ នោះច្បាស់ណាស់ថាពួកគេនឹងស្វែងរកអ្នកចេះដឹងផ្នែកច្បាប់ ជាពិសេសមេធាវីដើម្បីពិភាក្សា និងស្វែងរកដំណោះស្រាយចំពោះបញ្ហាដែលគេបានជួបប្រទះនោះ ដូចនេះមេធាវីមានតួនាទីសំខាន់ណាស់ ទាំងមុនពេលដាក់ពាក្យបណ្តឹង អំឡុងពេលដាក់ពាក្យបណ្តឹង អំឡុងពេលដំណើការនីតិវិធីនៃរឿងក្តី និង នៅក្រោយពេលបញ្ចប់សវនការ។ នៅក្នុងគ្រប់ រឿងក្តីទាំងអស់ មេធាវីត្រូវតែមានលិខិតប្រគល់សិទ្ធិ ឬ លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ឬ ពឹងពាក់ពីអតិថិជនរបស់ខ្លួន ដែលក្នុងលិខិតនោះត្រូវសរសេរលំអិតអំពីសិទ្ធិ និង តួនាទីរបស់មេធាវីដែលអតិថិជនប្រគល់សិទ្ធិឲ្យស្របតាមច្បាប់ និង គំរូដែលគណៈមេធាវីបានកំណត់[40]។

នៅពេលដែលមានជម្លោះផលប្រយោជន៍កើតឡើង គូភាគីតែងតែចង់ឈ្នះរាងខ្លួន ដូចនេះគេត្រូវការជំនួយផ្នែកច្បាប់ ដែលអាចផ្តល់យោបល់ និងមធ្យោបាយផ្លូវច្បាប់ដ៏មានប្រសិទ្ធិភាពសម្រាប់ពួកគេ ដូច្នេះគេត្រូវការមេធាវីដើម្បីពិគ្រោះពិភាក្សានូវបញ្ហារបស់ពួកគេ នៅមុនពេលដាក់ពាក្យបណ្តឹង ក្នុងគោលបំណងធ្វើយ៉ាងណាដើម្បីស្វែងរកដំណោះស្រាយចំពោះការការពារផលប្រយោជន៍របស់ពួកគេ។ ដូច្នេះយើងឃើញថា មេធាវី គឺមានតួនាទីសំខាន់នៅមុនពេលបណ្តឹងកើត

---

37 សៀវភៅនីតិវិធីសង្ខេបសម្រាប់អនុវត្តក្នុងរឿងក្តីរដ្ឋប្បវេណី សាស្ត្រាចារ្យ គី ប៊ុនទ្រាន

38 ក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា៧៤

39 សៀវភៅនីតិវិធីសង្ខេបសម្រាប់អនុវត្តក្នុងរឿងក្តីរដ្ឋប្បវេណី សាស្ត្រាចារ្យ គី ប៊ុនទ្រាន

40 មាត្រា២៣ នៃក្រមសីលធម៌មេធាវីនៃគៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១២

ឡើងផងដែរគឺ មេធាវីត្រូវពិគ្រោះនិងផ្តល់យោបល់ផ្នែកច្បាប់ដល់អតិថិជន ដែលការពិគ្រោះច្បាប់ជូនអតិថិជននេះគឺអាចធ្វើនៅការិយាល័យដើម ក្នុងការិយាល័យសាខារបស់ខ្លួន និង នៅទីកន្លែងផ្សេងទៀតដែលមានភាពសមរម្យ និងធានាបាននូវការសម្ងាត់វិជ្ជាជីវៈ[41]។ ម្យ៉ាងវិញទៀតនោះ នៅពេលដែលភាគីជម្លោះមានបំណងប្តឹងទៅតុលាការ គេត្រូវការមេធាវីដើម្បីសរសេរពាក្យបណ្តឹងឲ្យពួកគេដើម្បីសុំឲ្យតុលាការធ្វើការជំនុំជំរះ និងចេញសាលក្រមចំពោះការទាមទាររបស់គេ។ ដូចនេះ មេធាវីត្រូវសរសេរពាក្យបណ្តឹងសម្រាប់អតិថិជន ដើម្បីដាក់ទៅតុលាការដែលនៅក្នុងលិខិតនៃពាក្យបណ្តឹង ត្រូវសរសេរបញ្ជាក់នូវចំណុចដូចជាៈ

- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។
- ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ និង អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ។
- សរសេរបញ្ជាក់ឲ្យច្បាស់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារនិង តាមចំណុចដែលត្រូវការបញ្ជាក់ភស្តុតាង
- សរសេរពីមធ្យោបាយតទល់ ឬ ការពារខ្លួន សម្រាប់ជាឯកសារត្រៀមផង[42]។

**១. នីតិវិធីត្រៀមទាញហេតុផល**

នៅពេលមានការដាក់ពាក្យបណ្តឹងពីដើមបណ្តឹង តុលាការត្រូវធ្វើការជម្រះក្តី និងចេញសាលក្រមដោយការទាញហេតុផលដោយផ្ទាល់មាត់ ហើយដើម្បីធានាឱ្យបាននូវការជម្រះក្តីដោយការទាញហេតុផលដោយផ្ទាល់មាត់មួយជាទីពេញចិត្ត និង ទទួលបាននូវសាលក្រមមួយដែលឆ្លើយតបទៅនឹងការពិត ចាំបាច់ត្រូវតែមានការត្រៀមរៀបចំការទាញហេតុផលផ្ទាល់មាត់ ដូចនេះ នីតិវិធីត្រៀមទាញហេតុផល គឺត្រូវតែធ្វើឡើងមុនពេលការទាញហេតុផលផ្ទាល់មាត់[43]។ នីតិវិធីត្រៀមសម្រាប់ទាញហេតុផលគឺជានីតិវិធីនៃការត្រៀមរៀបចំសម្រាប់ការទាញហេតុដោយផ្ទាល់មាត់ ដែលអាចជួយសម្រួលដល់ការជម្រះក្តីនៅក្នុងការទាញហេតុផលផ្ទាល់មាត់ ដោយនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់នេះ គឺមានគោលបំណងធ្វើការបំភ្លឺអំពីចំណុចវិវាទរវាងភាគី ដោយរៀបចំជាមុននូវសេចក្តីអះអាងរបស់ភាគី និង ធ្វើការរៀបចំនូវភស្តុតាងពាក់ព័ន្ធនឹងចំណុចវិវាទដែល

[41] មាត្រា១៣ នៃក្រមសីលធម៌មេធាវីនៃគណៈមេធាវី ឆ្នាំ២០១២

[42] មើលមាត្រា៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[43] មើលមាត្រា១០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ត្រូវពិនិត្យ។ សម្រាប់នីតិវិធីនេះ តុលាការត្រូវកំណត់កាលបរិច្ឆេទលើកដំបូងក្នុងអំឡុងពេល ៣០ថ្ងៃ បន្ទាប់ពីថ្ងៃដែលពាក្យបណ្តឹងត្រូវបានដាក់[44]។

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះមេធាវីអាចតំណាងឱ្យកូនក្តីដើម្បីការពារផលប្រយោជន៍កូនក្តីរបស់ខ្លួនបាន នៅគ្រប់ដំណាក់កាលនីមួយៗនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ ដែលនីតិវិធីទាំងនោះគឺមានដូចជា ការរៀបចំដាក់ឯកសារត្រៀម ការសាកល្បងផ្សះផ្សា ការអះអាងរបស់គូភាគី ការបំភ្លឺចំណុចវិវាទ និងការពិនិត្យភស្តុតាងជាឯកសារ។

## ១.១. ការរៀបចំដាក់ឯកសារត្រៀម

នៅពេលធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចបង្គាប់ឱ្យភាគីដាក់ឯកសារត្រៀម ដែលនៅក្នុងឯកសារត្រៀមនោះត្រូវមានសរសេរអំពីមធ្យោបាយតទល់ ឬ ការពារខ្លួន និងសេចក្តីថ្លែងការណ៍ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួនរបស់ភាគីម្ខាងទៀត[45] ។ដូចនេះ មេធាវីដែលជាតំណាងដោយអាណត្តិឱ្យដើមចោទត្រូវតែរៀបចំនិងបញ្ជាក់ឱ្យបានច្បាស់លាស់ពីការទាមទារដែលកូនក្តីរបស់ខ្លួនចង់បាន ជាពិសេសត្រូវសរសេរពីអង្គហេតុសំខាន់ៗក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារនិងភស្តុតាង ។ រីឯមេធាវីចុងចម្លើយត្រូវសរសេរពីការឆ្លើយតប ចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានសរសេរទាមទារនៅក្នុងពាក្យបណ្តឹងនិង ការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង និង អង្គហេតុដើម្បីតវ៉ាចំពោះអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹងជាអាទិ៍[46]។

## ១.២. ការសាកល្បងផ្សះផ្សាក្នុងនីតិវិធីត្រៀមទាញហេតុផល

នៅក្នុងនីតិវិធីត្រៀមទាញហេតុផល តុលាការត្រូវតែធ្វើការសាកល្បងផ្សះផ្សាជាមុនសិន លើកលែងតែក្នុងករណីដែលយល់ថាមិនសមរម្យ[47]។ ការផ្សះផ្សាដែលធ្វើឡើងក្នុងនីតិវិធីនេះគឺអាចធ្វើឡើងដោយពីរដំណាក់កាល ដោយលើកដំបូងគឺជាការផ្សះផ្សាដែលធ្វើឡើងដោយមេធាវី និងលើកទី២គឺធ្វើឡើងដោយតុលាការ។ ហើយចំពោះការសាកល្បងផ្សះផ្សានេះ មេធាវីគឺមានតួនាទីសំខាន់ទាំងក្នុងការផ្សះផ្សាដែលធ្វើឡើងដោយមេធាវី និងធ្វើឡើងដោយតុលាការ។ ចំពោះការ

---

44 វាក្យខណ្ឌ២នៃមាត្រា៨០ នៃ ក្រមនីតិវិធីរដ្ឋប្បវេណី

45 មាត្រា១០១ នៃ ក្រមនីតិវិធីរដ្ឋប្បវេណី

46 វាក្យខណ្ឌ៣នៃមាត្រា១០១ នៃ ក្រមនីតិវិធីរដ្ឋប្បវេណី

47 មាត្រា១០៤ នៃ ក្រមនីតិវិធីរដ្ឋប្បវេណី

ផ្សះផ្សាដែលធ្វើឡើងដោយមេធាវី គឺមេធាវីដែលតំណាងឱ្យកូនក្តីនៃភាគីម្ខាងៗអាចសាកល្បងធ្វើការផ្សះផ្សា សម្របសម្រួលជាមួយភាគីម្ខាងទៀត ប្រសិនបើមានការឯកភាពពីកូនក្តីរបស់ខ្លួន។ មេធាវីត្រូវពិគ្រោះយោបល់ ហើយ សម្រុះសម្រួលភាគីដោយពន្យល់ណែនាំពីផលអវិជ្ជមាន និងការខាតបង់ទាំងពេលវេលា ក៏ដូចជាប្រាក់កាស ដែលបណ្តាលមកពីជម្លោះរបស់ពួកគេ បើគេត្រូវដោះស្រាយតាមផ្លូវតុលាការ។ ម្យ៉ាងវិញទៀត មេធាវីក៏អាចធ្វើការណាត់ជួបជាមួយភាគីទាំងសងខាងដើម្បីពិភាក្សា ជជែកទល់មុខផ្ទាល់ ដើម្បីរកដំណោះស្រាយដ៏សមស្របមួយដែលគូភាគីទាំងសងខាង អាចទទួលយកបាន និងរក្សាបានផលប្រយោជន៍នៃភាគីទាងពីរ។ បន្ទាប់ពីការផ្សះផ្សារបស់មេធាវី តុលាការត្រូវសាកល្បងធ្វើការផ្សះផ្សា ដែលការផ្សះផ្សានេះ ត្រូវធ្វើឡើងនៅពេលដែលភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ។ នៅពេលណែនាំឱ្យភាគីសះជាគ្នា តុលាការក៏អាចប្រើវិធីសាស្ត្រមួយ ដោយឱ្យភាគីម្ខាងចេញពីបន្ទប់ ហើយតុលាការស្តាប់ការអះអាងរបស់ភាគីម្ខាងទៀត និង ធ្វើដូច្នេះទៀតចំពោះភាគីម្ខាងទៀតបានដែរ តែវិធីនេះអាចប្រើបានតែក្នុងករណីដែលមានការព្រមព្រៀងច្បាស់លាស់រវាងគូភាគី។ មួយវិញទៀត ការផ្សះផ្សាដែលធ្វើឡើងដោយតុលាការនេះគឺតុលាការក៏អាចធ្វើការលុបចោលបានដែរ ប្រសិនបើ តុលាការមើលឃើញថាគូភាគី មិនមានឆន្ទៈ ឬអាកប្បកិរិយាក្នុងការសះជាគ្នាទេនោះ។

## ១.៣. ការធ្វើសេចក្តីថ្លែងការណ៍របស់គូភាគី

នីតិវិធីត្រៀមទាញហេតុផលផ្ទាល់មាត់ គឺមានគោលបំណងធ្វើការរៀបចំនូវការអះអាងរបស់ភាគី ធ្វើការកំណត់នូវចំណុចវិវាទ និង ជាពិសេសដើម្បីធ្វើការរៀបចំភស្តុតាងដែលទាក់ទងទៅនឹងចំណុចវិវាទ ដែលនៅក្នុងនីតិវិធីនេះ តុលាការត្រូវបង្គាប់ឱ្យភាគីដាក់ជាមុន នូវការអះអាង និង ភស្តុតាង ដែលពួកគេមានបំណងនឹងដាក់នៅពេលធ្វើការទាញហេតុផលផ្ទាល់មាត់។បន្ទាប់ពីភាគីបានដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនរួច តុលារការត្រូវអនុវត្តសិទ្ធិបំភ្លឺ និង រៀបចំការអះអាងរបស់ភាគីទាំងសងខាងដើម្បីកំណត់នូវចំណុចវិវាទនៃរឿងក្តីឱ្យបានច្បាស់លាស់ ហើយ តុលាការត្រូវរៀបចំភស្តុតាងពាក់ព័ន្ធនឹងចំណុចវិវាទនោះ ដែលត្រូវធ្វើការពិនិត្យនៅក្នុងការទាញហេតុផល ដែលវាជាផ្នែកសំខាន់ចាំបាច់បំផុតនៃការជម្រះក្តីនៅក្នុងនីតិវិធីត្រៀមសម្រាប់ទាញហេតុផល[48]។ បន្ទាប់មក ដើមចោទនឹងធ្វើសេចក្តីថ្លែងការណ៍គាំទ្រពាក្យសុំរបស់ខ្លួន (វិធីតទល់) ហើយចុងចម្លើយ នឹងធ្វើសេចក្តីថ្លែងការណ៍គាំទ្រពាក្យសុំរបស់ខ្លួនដែរ (វិធីការពារខ្លួន)។ ដូចច្នេះ ក្នុងដំណាក់កាលនេះមេធាវីនៃភាគីនីមួយៗត្រូវតំណាងឱ្យកូនក្តីរបស់ខ្លួនក្នុងការធ្វើសេចក្តីថ្លែងការដោយផ្ទាល់មាត់អំពី

[48] មើលមាត្រា១០៣នៃ ក្រមនីតិវិធីរដ្ឋប្បវេណី

ការទាមទារ អង្គហេតុសំខាន់ៗដែលបញ្ជាក់ពីការទាមទារ មូលហេតុនៃការទាមទារ(ចំពោះមេធាវីដើមចោទ) និង អំពីខ្លឹមសារ និង អង្គហេតុការពារខ្លួនឆ្លើយតបទៅនឹងការទាមទាររបស់ដើមចោទ (ចំពោះមេធាវីចុងចម្លើយ)។ មួយវិញទៀត មេធាវីទាំងសងខាងត្រូវដាក់មធ្យោបាយតទល់ ឬ ការពារខ្លួននោះទៅតាមពេលសមរម្យនៃដំណាក់កាលនៃរឿងក្តី[49]។

## ១.៤. ការបំភ្លឺចំណុចវិវាទ

នៅពេលដែលតុលាការយល់ឃើញថាការអះអាងរបស់គូភាគីមិនទាន់មានភាពច្បាស់លាស់ ឬ ការបញ្ជាក់ភស្តុតាងមិនទាន់គ្រប់គ្រាន់ដែលធ្វើឱ្យតុលាការមិនអាចកំណត់បាននូវអត្ថន័យ ឬ ចំណុចណាមួយច្បាស់លាស់នោះ តុលាការនឹងបង្គាប់ឱ្យគូភាគីធ្វើការបំភ្លឺអះអាង ឬ បញ្ជាក់ភស្តុតាងបន្ថែមទៀត។ដូចនេះក្នុងដំណាក់កាលនេះមេធាវីត្រូវរៀបចំការបំភ្លឺទាំងឡាយដាក់ជូនតុលាការពិនិត្យនៅក្នុងអំឡុងពេលដែលបានកំណត់ច្បាស់លាស់នោះឱ្យទាន់ពេលវេលាពីព្រោះ ប្រសិនបើការឆ្លើយតបនេះមានការយឺតយ៉ាវ វាអាចធ្វើឱ្យកូនក្តីរបស់ខ្លួនខូចខាតផលប្រយោជន៍។លើសពីនេះទៅទៀត រាល់ការបំភ្លឺចំណុចវិវាទទាំងនោះ មេធាវីត្រូវរៀបចំនិងពិនិត្យមើលឱ្យបានគ្រប់ជ្រុងជ្រោយដើម្បីធានាបាននូវការការពារផលប្រយោជន៍នៃកូនក្តីរបស់ខ្លួន ។

នៅពេលដែលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយបានបញ្ចប់នូវការរៀបចំចំណុចវិវាទនិងភស្តុតាងរួចហើយនោះតុលាការត្រូវបញ្ជាក់ជាមួយភាគីទាំងសងខាងអំពីអង្គហេតុដែលត្រូវធ្វើការបញ្ជាក់តាមរយៈការពិនិត្យភស្តុតាង នៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ដែលនឹងធ្វើបន្ទាប់ពីនោះ[50]។ គឺមានន័យថា តុលាការ និង ភាគីទាំងសងខាងត្រូវធ្វើការបញ្ជាក់ថាតើអង្គហេតុណាខ្លះដែលជាចំណុចវិវាទហើយដែលត្រូវជាកម្មវត្ថុនៃការពិនិត្យភស្តុតាង ដែលតុលាការ និង ភាគីសងខាងត្រូវមានការទទួលស្គាល់រួមគ្នាចំពោះបញ្ហានេះ ដើម្បីអាចធ្វើការពិនិត្យភស្តុតាងដោយសមូហវិធីនៅពេលទាញហេតុផលផ្ទាល់មាត់[51]។ ដូចនេះ មេធាវីនៃភាគីនីមួយៗត្រូវធ្វើការបញ្ជាក់ពីអង្គហេតុនៃចំណុចវិវាទណាដែលត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ ដែលធានាបាននូវផលប្រយោជន៍នៃកូនក្តីរបស់ខ្លួន។

## ១.៥. ការពិនិត្យភស្តុតាងជាឯកសារ

មេធាវីមានតួនាទីសំខាន់ក្នុងការសិក្សាស្វែងរកភស្តុតាងដែលមានអត្ថប្រយោជន៍សម្រាប់

---

[49] មើលមាត្រា៩៣នៃ ក្រមនីតិវិធីរដ្ឋប្បវេណី

[50] មើលមាត្រា១០៧នៃ ក្រមនីតិវិធីរដ្ឋប្បវេណី

[51] មើលមាត្រា១២៧នៃ ក្រមនីតិវិធីរដ្ឋប្បវេណី

កូនក្តីរបស់ខ្លួន ហើយរក្សាទុកភស្តុតាងនោះឱ្យបានល្អកុំឱ្យមានការខូចខាត ឬបាត់បង់ ដើម្បីដាក់ជូនតុលាការក្នុងការការពារអំណះអំណាងតទល់ ឬ អំណះអំណាងការពារខ្លួនរបស់ខ្លួន។ ម្យ៉ាងវិញទៀត មេធាវីក៏ត្រូវពិនិត្យមើលភស្តុតាងដែលខ្លួនមានឱ្យបានច្បាស់លាស់ផងដែរ នៅមុនពេលដាក់ភស្តុតាងនោះទៅតុលាការ ឬ ភាគីម្ខាងទៀត ដើម្បីធានាថាភស្តុតាងដែលខ្លួនមាននោះគឺជាភស្តុតាងដែលពិតត្រឹមត្រូវ ជៀសវាងពីការដាក់ភស្តុតាងក្លែងក្លាយដែលមិនអាចយកជាការបាន ហើយធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍នៃកូនក្តីរបស់ខ្លួន។ លើសពីនេះ មេធាវីក៏អាចស្នើសុំទៅតុលាការឱ្យពិនិត្យ និង ធ្វើកោសល្យវិច្ច័យ (ដោយអ្នកជំនាញ ឬ ស្ថាប័នផ្សេងៗដែលពាក់ព័ន្ធ)ទៅលើភស្តុតាងរបស់ភាគីម្ខាងទៀតដែលបានដាក់មកផងដែរ ប្រសិនបើមេធាវីសង្កេតឃើញថាមានបញ្ហា ឬ ភាពមិនប្រក្រតីណាមួយនៃភស្តុតាងនោះ។

**២. ដំណាក់កាលនីតិវិធីទាញហេតុផលផ្ទាល់មាត់**

ការទាញហេតុផលដោយផ្ទាល់មាត់ គឺជាទម្រង់មួយនៃការជម្រះក្តីរបស់តុលាការដែលក្នុងនោះសកម្មភាពរបស់តុលាការនិង សកម្មភាពរបស់ភាគីចំពោះការជម្រះក្តី ត្រូវធ្វើឡើងតាមរយៈការធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់ និង ការស្តាប់សេចក្តីថ្លែងការណ៍នោះនៅសាលសវនាការដោយបើកចំហជាសាធារណៈ [52] ។ ការទាញហេតុផលផ្ទាល់មាត់ត្រូវបានតុលាការកំណត់កាលបរិច្ឆេទ បន្ទាប់ពីនីតិវិធីត្រៀមទាញហេតុផលផ្ទាល់មាត់បានចប់សព្វគ្រប់ ហើយតុលាការត្រូវកោះហៅគូភាគីមកចូលរួមផងដែរ[53]។ ដំណាក់កាលទាញហេតុផលផ្ទាល់មាត់គឺមានគោលបំណងធានានូវគោលការណ៍ចំពោះមុខ ផ្តល់ឱកាសឱ្យភាគីទាំងសងខាង អាចធ្វើសេចក្តីថ្លែងការណ៍អំពីការអះអាងរបស់ខ្លួន ដោយយុត្តិធម៌ និង ស្មើភាពគ្នា និង ផ្តល់ឱកាសឱ្យភាគីអាចធ្វើការតវ៉ាចំពោះការអះអាងរបស់ភាគីម្ខាងទៀតផងដែរ។ ម្យ៉ាងវិញទៀត ការទាញហេតុផលផ្ទាល់មាត់នេះគឺមានគោលបំណងធានាឱ្យបានថា មុនពេលចេញសាលក្រម តុលាការ ពិតជាបានស្តាប់ការអះអាងរបស់ភាគីទាំងសងខាងដោយផ្ទាល់ ដែលវាជារឿងសំខាន់មួយដើម្បីបកស្រាយនូវការពិតនៃរឿងក្តី។

នៅក្នុងដំណាក់កាលនេះ មេធាវីមានតួនាទីសំខាន់ៗផ្សេងៗទៅតាមដំណាក់កាលនីមួយៗ ដូចជា ការសាកល្បងផ្សះផ្សា ការធ្វើសេចក្តីថ្លែងការណ៍ ការអះអាងបន្ថែម ឬការដាក់មធ្យោបាយតទល់ ឬការពារ និង នៅពេលបញ្ចប់ការទាញហេតុផលផ្ទាល់មាត់។

**២.១.ការសាកល្បងធ្វើការផ្សះផ្សាក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់**

[52] វាក្យខណ្ឌ២នៃមាត្រា១១៥នៃ ក្រមនីតិវិធីរដ្ឋប្បវេណី

[53] មាត្រា១១៧នៃ ក្រមនីតិវិធីរដ្ឋប្បវេណី

នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នេះ តុលាការអាចធ្វើការសាកល្បងផ្សះផ្សាភាគីសារជាថ្មីម្តងទៀតបាន បើទោះបីជា តុលាការធ្លាប់បានធ្វើការផ្សះផ្សានេះ មិនបានសះជានឹងគ្នានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលរួចហើយក៏ដោយ។ តែទោះបីជាយ៉ាងណាក៏ដោយ តុលាការក៏អាចមិនធ្វើការផ្សះផ្សានេះបានដែរបើសិនជាតុលាការមើលឃើញថាគ្មានភាគរយឬ ភាគរយនៃការសះជាមានតិចតួចបំផុតនោះ។ នៅក្នុងដំណាក់កាលនេះ មេធាវីដែលតំណាងឱ្យកូនក្តីនៃភាគីនីមួយៗត្រូវចូលរួមក្នុងដំណើរការផ្សះផ្សានេះ ដើម្បីឱ្យការផ្សះផ្សានេះធ្វើទៅបានដោយរលូន និង ការពារបាននូវផលប្រយោជន៍នៃកូនក្តីរបស់ខ្លួន។មេធាវីអាចទាក់ទងទៅកាន់មេធាវី ឬភាគីម្ខាងទៀតដើម្បីពិភាក្សាសម្របសម្រួល រកដំណោះស្រាយដើម្បីអាចសះជានឹងគ្នាដោយការពារបានផលប្រយោជន៍ដ៏សមស្របនៃភាគីទាំងសងខាង។

**២.២.ការធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

ជាគោលការណ៍ ការជម្រះក្តីលើបណ្តឹង គឺត្រូវធ្វើឡើងដោយការទាញហេតុផលដោយផ្ទាល់មាត់ ដោយសារវាជាភាពចាំបាច់មួយនៃការជម្រះក្តី[54] ដូចនេះហើយទើប តុលាការត្រូវធ្វើការកំណត់កាលបរិច្ឆេទនៃការទាញហេតុផលផ្ទាល់មាត់ បន្ទាប់ពីបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ ដើម្បីកោះភាគីទាំងសងខាងឱ្យមកចូលរួមនៅកាលបរិច្ឆេទនោះ ដើម្បីធ្វើការជម្រះក្តីដោយការទាញហេតុផលដោយផ្ទាល់មាត់។ ដូចនេះបន្ទាប់ពីការផ្សះផ្សាមិនបានសម្រេចរួចមក នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍ពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលសេចក្តីថ្លែងការណ៍នេះត្រូវធ្វើឡើងដោយចង្អុលបង្ហាញឱ្យបានច្បាស់លាស់នូវអង្គហេតុដែលនឹងត្រូវបញ្ជាក់ដោយការពិនិត្យភស្តុតាងនៅពេលក្រោយ នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់[55] ពោលគឺ ត្រូវបញ្ជាក់អំពីអង្គហេតុដែលបញ្ជាក់ តាមរយៈការពិនិត្យភស្តុតាងដែលនឹងត្រូវធ្វើនៅក្នុងនីតិវិធីនៃការទាញហេតុផលផ្ទាល់មាត់ គឺត្រូវបញ្ជាក់ឱ្យបានច្បាស់ពីអង្គហេតុដែលជាចំណុចវិវាទ។ ដូចនេះមេធាវីមានតួនាទីតំណាងឱ្យកូនក្តីរបស់ខ្លួនធ្វើសេចក្តីថ្លែងការណ៍ទាំងនោះ ដោយលើកឡើងនូវលទ្ធផលនៃនីតិវិធីត្រៀមទាញហេតុផល និង បញ្ជាក់ឱ្យបានច្បាស់ពីចំណុចវិវាទ។

**២.៣. ការដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនថ្មី**

[54] មើលមាត្រា១១៤នៃ ក្រមនីតិវិធីរដ្ឋប្បវេណី

[55] មើលមាត្រា១១៦នៃ ក្រមនីតិវិធីរដ្ឋប្បវេណី

បន្ទាប់ពីឆ្លងកាត់ការ ធ្វើសេចក្ដីថ្លែងការណ៍ពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវបន្តនីតិវិធីនៃការជម្រះក្តី ដោយការទាញហេតុផលផ្ទាល់មាត់។ ដំណាក់កាលនេះ ភាគីអាចធ្វើការដាក់មធ្យោបាយតទល់ ឬ ការពារថ្មីរបស់ខ្លួនបាន។ មធ្យោបាយតទល់ ឬ ការពារថ្មីដែលគូភាគីអាចដាក់ក្នុងដំណាក់កាលនេះបានគឺមានដូចជា មធ្យោបាយតទល់ ឬ ការពារខ្លួនដែលពាក់ព័ន្ធទៅនឹងបញ្ហាដែលតុលាការត្រូវធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់ខ្លួមធ្យោបាយតទល់ ឬ ការពារខ្លួនដែលមិនធ្វើឱ្យមានការយឺតយ៉ាវខ្លាំងដល់នីតិវិធីទោះបីជាមធ្យោបាយ នោះត្រូវបានលើកយកទៅពិនិត្យក៏ដោយ ហើយ មួយទៀតវិញនោះគឺ មធ្យោបាយតទល់ ឬ ការពារខ្លួនដែលភាគីបានធ្វើសេចក្តីបញ្ជាក់ដំបូងថា ការមិនអាចដាក់មធ្យោបាយនោះនៅមុនការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន មិនមែនបណ្តាលមកពីកំហុសធ្ងន់ធ្ងរឡើយ [56] ។ មួយវិញទៀត ក្នុងករណីដែល ភាគីអាចដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនថ្មីបាន ភាគីត្រូវតែដាក់មធ្យោបាយនោះនៅពេលសមរម្យ ក្នុងពេលធ្វើការទាញហេតុផលផ្ទាល់មាត់ ពីព្រោះបើ ភាគីធ្វើការដាក់មធ្យោបាយតទល់ ឬ ការពារខ្លួនថ្មីនៅពេលមិនសមរម្យ ហើយធ្វើឱ្យមានការយឺតយ៉ាវដល់នីតិវិធីតុលាការ នោះតុលាការអាចលើកចោលមធ្យោបាយនោះបាន[57]។ ដូចនេះ នៅក្នុងដំណាក់កាលនេះ មេធាវីអាចអះអាងបន្ថែមអំពីអង្គហេតុ និង ដាក់ភស្តុតាងថ្មីបន្ថែមទៀតបានផងដែរ។ លើសពីនេះ មេធាវីក៏អាចស្នើសុំឱ្យតុលាការចេញដីកាសម្រេច ដើម្បីធ្វើនីតិវិធីទាញហេតុផលជាថ្មីម្តងទៀតបាន បើខ្លួនយល់ឃើញថាវាពិតជាមានការចាំបាច់ក្នុងការធ្វើម្តងទៀតនោះ។

ម្យ៉ាងទៀត នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នេះ មេធាវីក៏អាចស្នើឱ្យតុលាការធ្វើការពិនិត្យភស្តុតាងដោយសម្ងហវិធី ដែល ត្រូវសាកសួរទៅលើសាក្សី[58] ឬ ធ្វើការសាកសួរសាមីភាគី [59]ដើម្បីបំភ្លឺអង្គហេតុដែលជាប្រយោជន៍នៃកូនក្តីរបស់ខ្លួន។ លើសពីនេះ មេធាវីអាចធ្វើការស្នើសុំតុលាការធ្វើកោសលវិច័យបានផងដែរ ដោយភ្ជាប់មកជាមួយនឹងឯកសារដែលពាក់ព័ន្ធដែលចង់ធ្វើកោសលវិច័យនោះ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនិងពិតប្រាកដនៃភស្តុតាងដែលបានដាក់ដោយភាគីម្ខាងទៀតនោះ[60] ។

[56] មាត្រា៩៤នៃ ក្រមនីតិវិធីរដ្ឋប្បវេណី

[57] មើលមាត្រា៩៣ និង ៩៤នៃ ក្រមនីតិវិធីរដ្ឋប្បវេណី

[58] មើលមាត្រា១៣៨ នៃ ក្រមនីតិវិធីរដ្ឋប្បវេណី

[59] មើលមាត្រា១៩០ នៃ ក្រមនីតិវិធីរដ្ឋប្បវេណី

[60] មើលមាត្រា១៨៣ នៃ ក្រមនីតិវិធីរដ្ឋប្បវេណី

ក្នុងដំណាក់កាលនេះ ប្រសិនបើតុលាការនៅមិនទាន់មានការជឿជាក់ទៅលើភស្តុតាងរបស់ភាគីទាំងសងខាង ឬក៏ការសួរដេញដោលនៅមិនទាន់ចប់សព្វគ្រប់ទេនោះ តុលាការអាចធ្វើការទាញហេតុផលនេះឡើងវិញជាច្រើនដងរហូតដល់តុលាការការមានការជឿជាក់ទៅលើភស្តុតាង និងចម្លើយនៃការសួរដេញដោលទាំងនោះ។

### ២.៤. ពេលបញ្ចប់ការទាញហេតុផលផ្ទាល់មាត់

នៅពេលដែលការពិនិត្យភស្តុតាងចប់សព្វគ្រប់ តុលាការត្រូវឱ្យភាគីធ្វើសេចក្តីថ្លែងការណ៍បញ្ចាក់ចុងក្រោយ មុនបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់[61]។ ដូចនេះមេធាវីត្រូវសរសេរពន្យល់អំពីសេចក្តីថ្លែងការណ៍នោះឱ្យបានច្បាស់លាស់ ដោយសង្ខេបអង្គហេតុនៃចំណុចវិវាទ រួមជាមួយការអះអាងដោយផ្អែកលើភស្តុតាង និង លើកយកហេតុផលដែលសមស្របត្រឹមត្រូវដែលអាចឱ្យតុលាការជឿទៅលើអ្វីដែលខ្លួនបានលើកឡើង។បន្ទាប់មកបើយល់ឃើញថា ត្រូវបញ្ចប់ការវិនិច្ឆ័យដោយផ្អែកទៅលើលទ្ធផលដែលបានមកពីការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យលើភស្តុតាង តុលាការត្រូវបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ និងបន្ទាប់មកត្រូវចេញសាលក្រមចុងក្រោយ[62]។

### ៣. ក្រោយពេលសវនាការ

នៅពេលដែលតុលាការបានចេញសាលក្រមរួច មេធាវីគឺនៅតែមានតួនាទីសំខាន់ក្នុងការជួយពន្យល់ និងណែនាំពីសិទ្ធិធ្វើបណ្តឹងឧបាស្រ័យ និងសិទ្ធិធ្វើបណ្តឹងសុំអនុវត្តសាលក្រមដល់កូនក្តីរបស់ខ្លួន។

### ៣.១. ពន្យល់ពីសិទ្ធិធ្វើបណ្តឹងឧបាស្រ័យដល់កូនក្តី

មេធាវីត្រូវពន្យល់ពីអត្ថន័យ នៃសាលក្រមដែលបានចេញដោយតុលាការនោះឱ្យ កូនក្តីរបស់ខ្លួនបានយល់ច្បាស់ ដើម្បី កូនក្តីបានយល់ត្រឹមត្រូវពីអត្ថន័យនៃការសម្រេចរបស់តុលាការចំពោះរឿងក្តី ហើយមេធាវីក៏ត្រូវតែធ្វើការពន្យល់ណែនាំកូនក្តីរបស់ខ្លួនផងដែរទាក់ទងនឹងសិទ្ធិនៃការធ្វើបណ្តឹងឧបាស្រ័យផងដែរ ដើម្បីឱ្យពួកគេយល់ និងអាចធ្វើការតវ៉ាបន្តទៅទៀតបានក្នុងករណីដែរពួកគេ មិនសុខចិត្តក្នុងការទទួលយកនូវការសម្រេចរបស់សាលាដំបូងដែលបានចេញសាលក្រមមកនោះ។

---

[61] វាក្យខណ្ឌ៥នៃមាត្រា១១៦ នៃ ក្រមនីតិវិធីរដ្ឋប្បវេណី

[62] វាក្យខណ្ឌ១នៃមាត្រា១៨០នៃ ក្រមនីតិវិធីរដ្ឋប្បវេណី

### ៣.២. ពន្យល់ពីសិទ្ធិធ្វើបណ្តឹងសុំអនុវត្តសាលក្រម

នៅពេលដែលតុលាការចេញសាលក្រមរួច ហើយគូភាគីព្រមទទួលយកសេចក្តីសម្រេចនោះ គេត្រូវធ្វើការដាក់ពាក្យស្នើសុំអនុវត្តសាលក្រមដែលបានចេញមកនោះ។ ដូចនេះមេធាវីត្រូវជួយកូនក្តីរបស់ខ្លួនក្នុងការសរសេរ និងដាក់ពាក្យស្នើសុំអនុវត្តសាលក្រម ដើម្បីធ្វើយ៉ាងណាអាចការពារបាននូវផលប្រយោជន៍នៃកូនក្តីរបស់ខ្លួន។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក មេធាវីគឺជាអ្នកដែលមានចំណេះដឹងជ្រៅជ្រះទូលំទូលាយម្នាក់ ជាពិសេសចំណេះដឹងផ្នែកច្បាប់ ដែលអាចធ្វើជាជំនួយ និង ផ្តល់យោបល់ដល់គូភាគីដែលមានជម្លោះដែលត្រូវការការណែនាំនិងផ្តល់យោបល់ផ្នែកច្បាប់ដើម្បីការពារផលប្រយោជន៍របស់ពួកគេបាន។ ហើយដើម្បីក្លាយជាមេធាវី និងអាចចូលប្រកបវិជ្ជាជីវៈបាននោះគឺ ត្រូវតែបំពេញតាមលក្ខខណ្ឌដែលមានកំណត់នៅក្នុងលក្ខន្តិកៈមេធាវី។

ឆ្លងតាមការសិក្សាស្រាវជ្រាវលើប្រធានបទនេះ យើងពិតជាឃើញហើយថាមេធាវីគឺពិតជាមានតួនាទីសំខាន់ណាស់នៅក្នុងដំណើរការនីតិវិធីតុលាការ ជាពិសេសនីតិវិធីរដ្ឋប្បវេណី។ មេធាវីមិនត្រឹមតែជាអ្នកពិភាក្សា ផ្តល់យោបល់ផ្នែកច្បាប់ដល់អតិថិជនតែប៉ុណ្ណោះនោះទេ មេធាវីថែមទាំងអាចតំណាងឱ្យកូនក្តីនៅជំណាក់កាលនីតិវិធីនីមួយៗ នៅក្នុងតុលាការផងដែរ។ ប្រសិនបើគ្មានមេធាវីដើម្បីជួយផ្តល់យោបល់ ឬតំណាងឱ្យកូនក្តីនៅក្នុងនីតិវិធីបណ្តឹងរដ្ឋប្បវេណីទេនោះ ដំណើរការនៃរឿងក្តីច្បាស់ជាជួបការលំបាកយ៉ាងខ្លាំង ដោយសារតែដើមបណ្តឹង ឬចុងចម្លើយជាប្រជាពលរដ្ឋធម្មតាដែលពួកគាត់មិនសូវបានយល់ដឹងអំពីនីតិវិធីនៃបណ្តឹង ហើយមិនដឹងថាត្រូវបំពេញ ឬធ្វើបែបណាទើបត្រឹមត្រូវទៅតាមនីតិវិធីតុលាការឡើយ ដែលកត្តានេះ អាចនាំឱ្យនីតិវិធីនៃបណ្តឹងមានការយឺតយ៉ាវ ដែលធ្វើឱ្យប៉ះដល់ប្រយោជន៍នៃភាគីទាំងសងខាង ទាំងពេលវេលា និងប្រាក់កាស និងជាពិសេសនោះគឺធ្វើឱ្យតុលាការជួបការស្មុគស្មាញ និង រឹតតែមានការមមាញឹកផងដែរ។ ដូចនេះយើងឃើញថា មេធាវីនៅក្នុងដំណើរការនៃនីតិវិធីរដ្ឋប្បវេណី គឺបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយការពារផលប្រយោជន៍ឱ្យកូនក្តី និងថែមទាំងជួយសម្រួលដល់នីតិវិធីតុលាការទៀតផង។ ដូចនេះដើម្បីឱ្យការបំពេញតួនាទីរបស់មេធាវី កាន់តែមានប្រសិទ្ធិភាព និងទទួលបានការទុកចិត្តពីអតិថិជននោះ មេធាវីគឺត្រូវតែប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួនឱ្យបានល្អខ្ជាប់ខ្ជួនជានិច្ច។

រាល់ថ្ងៃនេះ ជម្លោះនៃការដណ្តើមទាមទារផលប្រយោជន៍ចេះតែកើតមានឡើងជាបន្តបន្ទាប់កាន់តែច្រើន ដែលធ្វើឱ្យកំណើនអតិថិជនដែលត្រូវការជំនួយផ្នែកច្បាប់ពីមេធាវីក៏មានច្រើនដែរ ហើយយើងក៏មានការសំគាល់ឃើញផងដែរថា កំណើនមេធាវី និង ការិយាល័យមេធាវី ពីមួយឆ្នាំទៅមួយឆ្នាំក៏មានការកើនឡើងផងដែរ ហើយមកទល់ឆ្នាំ២០១៩នេះ មេធាវីសរុបទាំងអស់មាន

ចំនួនរហូតដល់ ១៧៧៣នាក់[63] ហើយយើងក៏រំពឹងផងដែរថាកំណើននេះនឹងមានការកើនឡើងជាបន្តបន្ទាប់ទៀតដើម្បីអាចជួយប្រជាពលរដ្ឋដែលត្រូវការជំនួយផ្នែកច្បាប់ និងជាពិសេសនោះគឺដើម្បីជាការចូលរួមលើកកម្ពស់វិស័យយុត្តិធម៌ នីតិរដ្ឋ និង ប្រជាធិបតេយ្យក្នុងប្រទេសរបស់យើងដែលជាកត្តាធ្វើឱ្យប្រទេសមានសណ្តាប់ធ្នាប់ របៀបរៀបរយ សុខសន្តិភាព និងការរីកចម្រើនកាន់តែខ្លាំងឡើងជាដរាប។

63 https://www.bakc.org.kh/index.php/2017-07-24-08-31-04

# អនុសាសន៍

# អនុសាសន៍

❖ ការប្រឡងជ្រើសរើសមេធាវីត្រូវកើតចេញពីភាពត្រឹមត្រូវ និង យុត្តិធម៌ ដើម្បីធ្វើយ៉ាងណាអាចរើសបាននូវអ្នកដែលមានសមត្ថភាពពិតប្រាកដ។ ដូចគ្នានេះដែរ ការអនុញ្ញាតឱ្យចូលប្រកបវិជ្ជាជីវៈមេធាវីតាមរយៈការស្នើសុំ ត្រូវធ្វើឡើងដោយភាពត្រឹមត្រូវ ដោយបំពេញទៅតាមលក្ខខណ្ឌដែលបានកំណត់។

❖ ការបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីត្រូវតែធានាបាននូវប្រសិទ្ធភាព និងគុណភាពទាំងចំណេះដឹងនិង សីលធម៌វិជ្ជាជីវៈ។ហើយមេធាវីខ្លួនឯងផ្ទាល់ក៏ត្រូវខិតខំសិក្សាស្វែងយល់បន្ថែមឱ្យបានច្រើនទាំងចំណេះដឹងផ្នែកច្បាប់និងសង្គម ជាពិសេសត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈភាពសុចរិតនិងភាពស្មោះត្រង់ចំពោះអតិថិជន។

❖ មេធាវីត្រូវដឹងឱ្យបានច្បាស់លាស់ពីនីតិវិធីតុលាការក្នុងរឿងក្តីរដ្ឋប្បវេណីហើយនៅក្នុងពេលដំណើរការរឿងក្តី មេធាវីត្រូវយកចិត្តទុកដាក់សហការ និង បំពេញតួនាទីរបស់ខ្លួនទៅតាមដំណាក់កាលនៃនីតិវិធីនីមួយៗនោះឱ្យបានត្រឹមត្រូវ។មេធាវីមិនត្រូវបង្អាក់ ឬ ធ្វើឱ្យមានកំហុសណាមួយកើតឡើង ដែលនាំឱ្យនីតិវិធីតុលាការមានការយឺតយ៉ាវ និង ជាពិសេសដែលធ្វើឱ្យខាតប្រយោជន៍នៃកូនក្តីរបស់ខ្លួននោះឡើយ។

❖ នៅពេលធ្វើការផ្សះផ្សារវាងគូភាគីទាំងពីរ ទាំងការផ្សះផ្សាដោយមេធាវី និងការផ្សះផ្សាដោយតុលាការ មេធាវីគួរខិតខំឱ្យអស់ពីសមត្ថភាពក្នុងការពន្យល់ណែនាំ និង សម្របសម្រួលឱ្យគូភាគីទាំងសងខាងមានការសះជានឹងគ្នា ដើម្បីឱ្យអាចរក្សាបាននូវផលប្រយោជន៍នៃគូភាគីទាំងសងខាង។

❖ មេធាវីត្រូវខិតខំឱ្យអស់ពីសមត្ថភាពក្នុងការស្វែងរក និង ប្រមូលភស្តុតាងដាក់ទៅតុលាការដើម្បីគាំទ្រលើអំណះអំណាងរបស់ខ្លួនដែលបានលើកឡើង ធ្វើយ៉ាងណាដើម្បីអាចការពារបាននូវផលប្រយោជន៍នៃកូនក្តីរបស់ខ្លួន។ ម្យ៉ាងវិញទៀត មេធាវីមិនត្រូវប្រើមធ្យោបាយទុច្ចរិត ឬខុសច្បាប់ណាមួយដើម្បីឱ្យបានឈ្នះក្តីនោះឡើយ។

# ឯកសារយោង

# បញ្ជីឯកសារយោង

- **បទដ្ឋានគតិយុត្ត**
  - រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។
  - ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា អនុម័តថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០០៦។
  - ច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី ប្រកាសឲ្យប្រើដោយរដ្ឋសភា នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ១៩៩៥។
  - អនុក្រឹត្យស្ដីពី ការបង្កើតមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈមេធាវី ឆ្នាំ២០០៨។
  - ក្រមសីលធម៌មេធាវី នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា រៀបរៀងដោយ គណៈមេធាវី ឆ្នាំ២០១២។
  - បទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជារៀបរៀងដោយគណៈមេធាវី នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦។
  - សេចក្ដីសម្រេចស្ដីពីនីតិវិធីទទួលពិនិត្យ និង សម្រេចលើពាក្យសុំចូលប្រកបវិជ្ជាជីវៈ មេធាវីតាមមាត្រា ៣២នៃច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី ដែលត្រូវបានអនុម័តដោយក្រុម ប្រឹក្សាគណៈមេធាវី នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧។
- **សៀវភៅ**
  - សៀវភៅ សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋបវេណី ភាគ១ រៀបចំដោយក្រុមការងារ ជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា។
  - សៀវភៅនីតិវិធីសង្ខេបសម្រាប់អនុវត្តក្នុងរឿងក្ដីរដ្ឋប្បវេណីសាស្ត្រាចារ្យ គី ប៊ុនទ្រាន ឆ្នាំ២០១៦។
- **គេហទំព័រ**
  - https://www.bakc.org.kh/
  - https://www.bakc.org.kh/index.php/2017-07-24-08-31-04
  - https://www.bakc.org.kh/index.php/2017-07-24-08-31-33

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

---

## ពាក្យសុំតំណាងមេធាវី

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.......................អាយុ...........ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.........ផ្លូវលេខ..........ឃុំ/សង្កាត់..........................ស្រុក/ខណ្ឌ.........................រាជធានី/ខេត្ត...........................។

## សូមតំណាង

មេធាវី **តាំង គុងហាង** អត្តលេខៈ ១២៨០T ជាមេធាវីនៃ ក្រុមហ៊ុនមេធាវី ខ្មែរអប្សរា ដែលមានការិយាល័យផ្ទះលេខ ៨អ ផ្លូវលេខ ២៨៥ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីធ្វើជាមេធាវីការពារសិទ្ធិឲ្យខ្ញុំបាទ/នាងខ្ញុំ នៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ.......ចុះថ្ងៃទី.......ខែ.......ឆ្នាំ ២០១៧ របស់សាលាដំបូង...............................។

លោក មេធាវី ដែលបានទទួលសិទ្ធិការពារនៅក្នុងសំណុំរឿងក្តីនេះ មានសិទ្ធិអំណាចធ្វើជំនួសនូវរាល់បណ្តឹងដែលពាក់ព័ន្ធក្នុងរឿងក្តីគ្រប់ដំណាក់កាល នៃនីតិវិធីរបស់តុលាការ និងធ្វើនូវរាល់សកម្មភាព ដែលស្របទៅនឹងស្មារតីច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃដែលខ្ញុំបាទ/នាងខ្ញុំផ្តិតមេដៃតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី.....ខែ.........ឆ្នាំ ២០១៧
**ស្នាមមេដៃស្តាំ**

បានឃើញ និងយល់ព្រម
រាជធានីភ្នំពេញ ថ្ងៃទី.....ខែ..........ឆ្នាំ ២០១៧
**ហត្ថលេខា និងត្រា**

បានឃើញ និងយល់ព្រម
រាជធានីភ្នំពេញ ថ្ងៃទី.....ខែ..........ឆ្នាំ ២០១៧
**គ្រូកម្មសិក្សា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

---

## លិខិតតំណាងដោយអាណត្តិ

មេធាវីឈ្មោះ ................ អត្តលេខ......... និងលោកស្រីមេធាវី ................ អត្តលេខ ....... មានការិយាល័យឈ្មោះ ........................ មានទីតាំងស្ថិតនៅផ្ទះលេខ៥៧-៥៩ផ្លូវបេតុង ក្រុមទី៣ ភូមិត្រា៨ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

**សូមគោរពជូន**

**លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ:** ស្តីពីមេធាវីតំណាងដោយអាណត្តិអោយឈ្មោះ..................នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ .......... ចុះថ្ងៃទី....... ខែ.......... ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ។

**យោង:** - ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី
- ក្រមនីតិវិធីរដ្ឋប្បវេណី
- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់ឈ្មោះ................... ចុះថ្ងៃទី .......... ខែ......... ឆ្នាំ២០១៩។

តបតាមកម្មវត្ថុ និង យោងខាងលើ យើងខ្ញុំសូមជំរាបជូន **លោកប្រធាន** មេត្តាជ្រាបថា៖ អាណត្តិទាយកឈ្មោះ.............................. បានប្រគល់សិទ្ធិអោយយើងខ្ញុំធ្វើជាមេធាវីតំណាងដោយអាណត្តិនៅក្នុងសំណុំរឿងរដ្ឋប្បវេណី ដូចនៅក្នុងកម្មវត្ថុខាងលើ។

អាស្រ័យហេតុនេះសូម **លោកចៅក្រម** មេត្តាជ្រាបតាមនីតិវិធីច្បាប់ចាប់ពីពេលនេះតទៅ។
សូមលោកទទួលការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី........ ខែ......... ឆ្នាំ២០១៩

**ហត្ថលេខា និង ត្រាមេធាវី**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

---

# លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

អាណត្តិទាយកឈ្មោះ: .................................. ភេទ.............. អាយុ.............. ឆ្នាំ ជាតិ.............. អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ .............. ផ្លូវលេខ.............. ក្រុម.............. ភូមិ/មណ្ឌល.............. ឃុំ/សង្កាត់/.............................. ស្រុក/ខណ្ឌ/ក្រុង.............................. ខេត្ត/រាជធានី.............................. និងឈ្មោះ:.............................. ភេទ.............. អាយុ.............. ឆ្នាំ ជាតិ .............. អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ .............. ផ្លូវលេខ.............. ក្រុម.............. ភូមិ/មណ្ឌល.............................. ឃុំ/សង្កាត់.............................. ស្រុក/ខណ្ឌ/ក្រុង.............................. ខេត្ត/រាជធានី..................................។

## សូមប្រគល់សិទ្ធិជូន

លោកមេធាវី .............................. អត្តលេខ.............. និងលោកមេធាវី .............................. អត្តលេខ.............. មានការិយាល័យឈ្មោះ .............................. មានទីតាំងស្ថិតនៅផ្ទះលេខ៥៧-៥៩ ផ្លូវបេតុង ក្រុមទី៣ ភូមិត្រពាំង សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឱ្យធ្វើជា **អ្នកតំណាងដោយអាណត្តិ** របស់យើងខ្ញុំ ក្នុងការ.................................................................... ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ .............................. ចុះថ្ងៃទី.......... ខែ.............. ឆ្នាំ.............. របស់..................................................។

***បញ្ជាក់:*** សោហ៊ុយចំណាយលើការបង់ពន្ធផ្សេងៗ នៅក្នុងបណ្តឹងនេះជាបន្ទុករបស់ ខ្ញុំបាទ/នាងខ្ញុំ អាណត្តិទាយក។ ក្នុងករណីមិនបានគោរពនូវកាតព្វកិច្ចនេះ ខ្ញុំបាទ/នាងខ្ញុំ អាណត្តិទាយកសុខចិត្តទទួលខុសត្រូវរាល់ការបាត់បង់ផលប្រយោជន៍នានាដោយខ្លួនឯងផ្ទាល់។

លោកមេធាវីតំណាងដោយអាណត្តិ មានសិទ្ធិអនុវត្តនូវកិច្ចការអាណត្តិតាមច្បាប់ ដែលអាណត្តិទាយកបានប្រគល់ជូនដូចខាងលើ ចាប់ពីថ្ងៃផ្តិតមេដៃ ឬ ចុះហត្ថលេខានេះតទៅ។

.............................. ថ្ងៃទី.......... ខែ.............. ឆ្នាំ..............

**អាណត្តិទាយក**

បានឃើញ និង យល់ព្រម

ធ្វើជាមេធាវីតំណាងឲ្យអាណត្តិទាយក

.............................. ថ្ងៃទី.......... ខែ.............. ឆ្នាំ..............

**ហត្ថលេខា និងត្រាមេធាវី**

សាលាដំបូងរាជធានីភ្នំពេញ
ចូល ថ្ងៃ 17 ខែ 5 ឆ្នាំ 2019

សាលាដំបូងរាជធានីភ្នំពេញ
លេខ 2619033603
17 ខែ 5 ឆ្នាំ 2019

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

---

## ពាក្យបណ្តឹង

***ដើមចោទ៖*** ឈ្មោះ សៀង ធីលី ភេទស្រី ជាពលរដ្ឋខ្មែរ កើតថ្ងៃទី២៣ ០៤ ១៩៩២ កាន់អត្តសញ្ញាណ បណ្ណលេខ០១១៣២៣៨១៦ ចុះថ្ងៃទី២៣ ០៨ ២០១៨ មានអាសយដ្ឋានផ្ទះលេខ៣៨៦ ផ្លូវ៣១ ភូមិ៨ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

***មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ៖*** លោកមេធាវី អត្តលេខ និងលោកមេធាវី អត្តលេខ១២៣៩ មានការិយាល័យឈ្មោះ: ***អេច ភី អេ និងសហការី***

***សហចុងចោទ៖*** ឈ្មោះ ភេទប្រុស ជាពលរដ្ឋខ្មែរ កើតថ្ងៃទី១២ ១១ ១៩៨០ កាន់អត្តសញ្ញាណបណ្ណលេខ០១០២៦០៩៩៤(០១) ចុះថ្ងៃទី១៩ ០៨ ២០១៨ និងប្រពន្ធឈ្មោះ: ជាពលរដ្ឋខ្មែរ កើតថ្ងៃទី០៩ ០៩ ១៩៨២ កាន់អត្តសញ្ញាណបណ្ណលេខ០១០០៤៨៣៦៩ ចុះថ្ងៃ ទី១៥ ០៦ ២០១៩មានអាសយដ្ឋានផ្ទះលេខ៣៨ ភូមិ៨ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ និងឈ្មោះ: ជាពលរដ្ឋខ្មែរ កើតថ្ងៃទី០២ ០៣ ១៩៩១ កាន់អត្តសញ្ញាណ បណ្ណលេខ ០១០០៤៦០៨២ (០១) ចុះថ្ងៃទី១៥ ០៦ ២០១៥ និងប្រពន្ធឈ្មោះ: ជាពលរដ្ឋខ្មែរ កើតថ្ងៃទី០៩ ០២ ១៩៩៣ កាន់អត្តសញ្ញាណបណ្ណលេខ០១០០៤៦០៨៣(០១) ចុះថ្ងៃទី១៥ ០៦ ២០១៥ មានអាសយដ្ឋានផ្ទះលេខ ៣០គឺ០ ផ្លូវ១៣០ ភូមិ២ សង្កាត់ផ្សារថ្មីទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

### សូមគោរពជូន
### លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ

<u>*សូមមេត្តាជ្រាប*</u>។

**កម្មវត្ថុ ៖ ប្តឹងសុំឲ្យតុលាការចេញសាលក្រម ដែលមានខ្លឹមសារដូចខាងក្រោម៖**

១.បង្គាប់ឱ្យចុងចោទ ទាំងអ្នកសុំខ្ចី និងអ្នកធានាបំណុល ត្រូវបង់ប្រាក់ដើមចំនួនUSD១៣០.០០០ (ដប់បីម៉ឺន )ដុល្លាអាមេរិក សងមកឲ្យដើមចោទ។

២.បង្គាប់ឱ្យចុងចោទ ទាំងអ្នកសុំខ្ចី និងអ្នកធានាបំណុលត្រូវបង់ការប្រាក់ចំនួន ០២%(ពីរភាគរយ) ក្នុងមួយខែ លើសមតុល្យនៃប្រាក់ដើមចំនួន USD១៣០,០០០ (ដប់បីម៉ឺន)ដុល្លាអាមេរិក គិតចាប់ពីថ្ងៃទី ១៥ ខែតុលា ឆ្នាំ២០១៨ <u>រហូតដល់ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៩ មានចំនួនស្មើនឹង USD១០,៤០០ (មួយម៉ឺនបួនរយ) ដុល្លាអាមេរិក</u> សងបង្រ្គប់ទៅឱ្យដើមចោទ។

៣.បង្គាប់ឱ្យចុងចោទ ទាំងអ្នកសុំខ្ចី និងអ្នកធានាបំណុល ត្រូវបង់ការប្រាក់យឺតយ៉ាវចំនួន៤៨%(សែសិបប្រាំបី)ភាគរយ ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន USD១៣០ ០០០ (ដប់បីម៉ឺន) ដុល្លាអាមេរិក គិតចាប់ពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៨ រហូតដល់កាលបរិច្ឆេទបង់ប្រាក់គ្រប់ចំនួន ជូនទៅឱ្យ ដើមចោទ។



ង.បង្គាប់ឱ្យចុងចម្លើយ ទាំងអ្នកខ្ចី និងអ្នកធានាបំណុល រួមគ្នាបង់ការប្រាក់ពិន័យលើការពន្យារពេលចំនួន២០% (ម្ភៃភាគរយ) ក្នុងមួយឆ្នាំ ឬ០២%(ពីរភាគរយ) ក្នុងមួយខែ នៃប្រាក់ការដែលមិនបានបង់ឱ្យដើម ចោទ គិតចាប់ពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ រហូតដល់ពេលពិតជាបង់ប្រាក់គ្រប់ចំនួន ទៅឱ្យដើមចោទ។

ច.បង្គាប់ឱ្យចុងចម្លើយ ទាំងអ្នកខ្ចី និងអ្នកធានាបំណុល រួមគ្នាសងប្រាក់ថ្លៃ ខាតបង់ពេលវេលា និងជំងឺចិត្ត រួមទាំងសោហ៊ុយចំណាយផ្សេងៗ ក្រៅពីសេវាមេធាវីក្នុងបណ្ដឹងចំនួន USD ៥០.០០០ (ហាម៉ឺន) ដុល្លារអាមេរិក ទៅឱ្យដើមចោទ។

ឆ.បង្គាប់ឱ្យចុងចម្លើយ ទាំងអ្នកខ្ចី និងអ្នកធានាបំណុលរួមគ្នាសងប្រាក់ថ្លៃបង់ពន្ធលើពាក្យបណ្ដឹង និងប្រាក់ប្រដាប់ក្ដី ទៅឱ្យដើមចោទ។

ជ.សុំឱ្យប្រកាសដាក់សាលក្រមនេះ ឲ្យអនុវត្តជាបណ្ដោះអាសន្ន។

**ភស្តុតាងបញ្ជាក់អំពីការទាមទារ៖**

- កិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨
- លិខិតបញ្ជាក់ទទួលប្រាក់ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨
- លិខិតធានាដោយតតិយជន ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨
- លិខិតជូនដំណឹង ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨

**អង្គហេតុ និងមូលហេតុបញ្ជាក់អំពីការទាមទារ ៖**

**អង្គហេតុ បញ្ជាក់អំពីការទាមទារ ៖**

កាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ សហចុងចម្លើយបានចុះខ្ចីប្រាក់ពីនាងខ្ញុំ ចំនួនUSD ១៣០.០០០ (ដប់បីម៉ឺន) ដុល្លារអាមេរិក តាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨។ នាងខ្ញុំបានប្រគល់ប្រាក់ជូនកូនបំណុល និងកូនបំណុលបានទទួលប្រាក់ ចំនួនUSD១៣០.០០០(ដប់បីម៉ឺន)ដុល្លារអាមេរិក រួចហើយក្នុងថ្ងៃចុះកិច្ចសន្យា (លិខិតបញ្ជាក់ទទួលប្រាក់ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨) ដោយនាងខ្ញុំរង់ចាំទទួលការបង់ការប្រាក់ និងប្រាក់ដើមពីសហចុងចម្លើយ។

ចាប់ពីថ្ងៃខ្ចីបរិភោគមក បានកន្លងផុតជិត០៥ខែមកហើយ ដែលសហចុងចម្លើយ ពុំបានអនុវត្តកាតព្វកិច្ចរបស់ខ្លួន ក្នុងការបង់ការប្រាក់ជូននាងខ្ញុំឡើយ។ ការមិនបង់ការប្រាក់ និងប្រាក់ដើម តាមខ្លឹមសារនៃកិច្ចព្រមព្រៀង ខ្ចីបរិភោគខាងលើ គឺជាការបំពានកិច្ចសន្យាធ្ងន់ធ្ងរ។ ជាងនេះទៅទៀត កិច្ចសន្យាខ្ចីបរិភោគនេះ កូនបំណុល និងអ្នកធានា បានព្រមព្រៀងដាក់ទ្រព្យធានាលើអចលនទ្រព្យ មួយកន្លែង ដែលមានលិខិតសម្គាល់ "ពាក្យស្នើសុំផ្ទេរកម្មសិទ្ធិលេខ ២២ ស ៖ ៨ ស ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៩៦" (ប្រការ៨ នៃកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨)។

រហូតមកទល់នឹងបច្ចុប្បន្ននេះ កូនបំណុលនិងអ្នកធានា មិនត្រឹមតែមិនអនុវត្តបង់ការប្រាក់ចំនួន០៤ខែទេ និងថែមទាំងមិនបានបង់ប្រាក់ដើមចំនួន USD១៣០.០០០(ដប់បីម៉ឺន)ដុល្លារអាមេរិកថែមទៀត ដោយកូនបំណុល និងអ្នកធានា បានទទួលប្រាក់ពីការលក់ផ្ទះមួយកន្លែងដែលមានលេខ៣០អឺ ផ្លូវ១៣០ ភូមិ២ សង្កាត់ផ្សារចាស់ទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ជាងនេះទៅទៀត កូនបំណុល និងអ្នកធានា បានបង្វែរគេចវេស និងមិនសហការ ទូទាត់បំណុល ជូនមកនាងខ្ញុំឡើយ ទោះបីនាងខ្ញុំព្យាយាមទាក់ទង និងបានជូនដំណឹងត្រឹមត្រូវតាមផ្លូវច្បាប់ ក៏ដោយ។



**មូលហេតុ និងសំអាងហេតុ បញ្ជាក់ពីការទាមទារ៖**

១. បង្គាប់ឱ្យចុងចម្លើយ ទាំងអ្នកសុំខ្ចី និងអ្នកធានាបំណុល រួមគ្នាសងប្រាក់ដើមចំនួន USD
១៣០,០០០ (ដប់បីម៉ឺន)ដុល្លារអាមេរិក សងមកឱ្យដើមចោទ **ដោយសំអាងហេតុថា៖** កាលពីថ្ងៃទី០៥ ខែ
តុលា ឆ្នាំ២០១៨ សហព្ធ ចម្លើយឈ្មោះ: **ទឹម ចាន់ថា** និងឈ្មោះ: **គួច សុភមង្គល** (អ្នកសុំខ្ចី) បានខ្ចីប្រាក់ពី
ដើមចោទចំនួន USD១៣០,០០០ (ដប់បីម៉ឺន)ដុល្លារអាមេរិក និងមានចុងចម្លើយឈ្មោះ: **គួច សុភាព** និងឈ្មោះ:
**ស្រ៊ុន ចន្ថា** ជាអ្នកធានាចំពោះការខ្ចី ប្រាក់ខាងលើ ដូចមានចុះលិខិតធានាដោយគតិយុត្តចុះថ្ងៃទី០៥ ខែ
តុលា ឆ្នាំ២០១៨ ដូចនេះកូនបំណុល និងអ្នកធានាត្រូវមានកាតព្វកិច្ចរួមគ្នាសងប្រាក់ដើមមកម្ចាស់បំណុលវិញ។

២. បង្គាប់ឱ្យចុងចម្លើយ ទាំងអ្នកសុំខ្ចី និងអ្នកធានាបំណុល រួមគ្នាបង់ការប្រាក់ចំនួន ០២%(ពីរភាគ
រយ) ក្នុងមួយខែ លើសមតុល្យនៃប្រាក់ដើមចំនួន USD១៣០,០០០ (ដប់បីម៉ឺន)ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី
១៥ ខែតុលា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩ មានចំនួនស្មើនឹង USD១០,៤០០ (មួយម៉ឺន
បួនរយ) ដុល្លារអាមេរិក សងបង្គ្រប់ទៅឱ្យដើមចោទ **ដោយសំអាងហេតុថា៖** តាមប្រការ៤ នៃកិច្ចព្រមព្រៀងខ្ចី
ប្រាក់ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ ២០១៨ គឺកូនបំណុលត្រូវមានកាតព្វកិច្ចបង់ការប្រាក់ជូនចំនួន០២%(ពីរភាគ
រយ) ក្នុងមួយខែ លើសមតុល្យ នៃប្រាក់ ដើមចំនួន USD១៣០,០០០ (ដប់បីម៉ឺន)ដុល្លារអាមេរិក គិតចាប់ពីថ្ងៃ
ទី១៥ ខែតុលា ឆ្នាំ២០១៨។ ភាគីកូនបំណុល អាក់ខានមិនបានបង់ការប្រាក់គិតចាប់ពីថ្ងៃទី១៥ ខែតុលា ឆ្នាំ
២០១៨ រហូតដល់ថ្ងៃទី១៥ ខែកុម្ភៈឆ្នាំ២០១៩។ ដូចនេះ ការប្រាក់មានចំនួនស្មើនឹងUSD១០,៤០០ (មួយ
ម៉ឺនបួនរយ) ដុល្លារអាមេរិក។

៣. បង្គាប់ឱ្យចុងចម្លើយ ទាំងអ្នកសុំខ្ចី និងអ្នកធានាបំណុល រួមគ្នាបង់ការប្រាក់យឺតយ៉ាវចំនួន៤៨%
(សែសិបប្រាំបី)ភាគរយ ក្នុងមួយឆ្នាំ នៃប្រាក់ដើមចំនួន USD១៣០,០០០ (ដប់បីម៉ឺន)ដុល្លារអាមេរិក គិតចាប់
ពីថ្ងៃទី១៥ ខែវិច្ឆិកាឆ្នាំ២០១៨ រហូតដល់កាលបរិច្ឆេទបង់ប្រាក់គ្រប់ចំនួនទៅឱ្យដើមចោទ **ដោយសំអាង
ហេតុថា៖** តាមប្រការ៥ នៃកិច្ចព្រមព្រៀងខ្ចីប្រាក់ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ បានចែងថាករណីម្ចាស់
បំណុល មិនបានទទួលប្រាក់គ្រប់ចំនួនទាំងអស់ ដែលភាគីកូនបំណុលត្រូវសងតាមកាលបរិច្ឆេទកំណត់សង
នោះ ភាគីកូន បំណុលត្រូវបង់ប្រាក់ជូនម្ចាស់ បំណុលនូវចំនួន៤៨%(សែសិបប្រាំបី)ភាគរយ ក្នុងមួយឆ្នាំ នៃ
ប្រាក់កម្ចីដែលមិនបានបង់ នៅថ្ងៃដល់កំណត់សង ចាប់ពីកាលបរិច្ឆេទបន្ទាប់នៃថ្ងៃដល់កំណត់សង។

៤. បង្គាប់ឱ្យចុងចម្លើយ ទាំងអ្នកសុំខ្ចី និងអ្នកធានាបំណុល រួមគ្នាបង់ការប្រាក់ពិន័យលើការយឺត
យ៉ាវចំនួនចំនួន២៤%(ម្ភៃបួន)ភាគរយ ក្នុងមួយឆ្នាំ ឬ០២%(ពីរ)ភាគរយ ក្នុងមួយខែ នៃប្រាក់ការដែលមិនបាន
បង់ឱ្យដើមចោទ គិតចាប់ពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៨ រហូតដល់កាលបរិច្ឆេទបង់ប្រាក់គ្រប់ចំនួន ទៅឱ្យ
ដើមចោទ **ដោយសំអាងហេតុ ថា៖** តាមប្រការ៥ នៃកិច្ចព្រមព្រៀងខ្ចីប្រាក់ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨
បានចែងថាករណីម្ចាស់បំណុល មិនបាន ទទួលប្រាក់គ្រប់ចំនួនទាំងអស់ ដែលភាគីកូនបំណុលត្រូវសងតាម
កាលបរិច្ឆេទកំណត់សងនោះ: ភាគីកូនបំណុល ត្រូវបង់ប្រាក់ពិន័យជូនម្ចាស់បំណុលនូវចំនួន២៤%(ម្ភៃបួន)
ភាគរយ ក្នុងមួយឆ្នាំ ឬ០២%(ពីរ)ភាគរយ ក្នុងមួយខែ នៃការប្រាក់កម្ចីដែលមិនបានបង់។

៥.បង្គាប់ឱ្យចុងចម្លើយ ទាំងអ្នកសុំខ្ចី និងអ្នកធានាបំណុល រួមគ្នាសងប្រាក់ថ្លៃ ខាតបង់ពេលវេលា
និងជំងឺ ចិត្ត រួមទាំងសោហ៊ុយចំណាយផ្សេងៗ ក្រៅស្រាវជ្រាវ ក្រៅពីមេធាវីចំនួនUSD៥០,០០០ (ប្រាំម៉ឺន)
ដុល្លារអាមេរិក ទៅឱ្យដើមចោទ **ដោយសំអាងហេតុថា៖** ចុងចម្លើយ និងអ្នកធានាជាអ្នករំលោភលើកិច្ចព្រម
ព្រៀងខ្ចីប្រាក់ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ និងលិខិតធានាដោយគតិយុត្តចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ



២០១៨។ ការមិនអនុវត្តកិច្ចសន្យាពី សំណាក់កូនបំណុល និងអ្នកធានា គឺធ្វើឲ្យខាតបង់ដល់ខាងម្ចាស់បំណុល ខាតបង់ពេលវេលា និងការ ចំណាយផ្សេងៗ ហើយសេចក្តីក្រៅផ្លូវរបស់ខាងដើម ដែលផ្សេងៗទៀត។

ខ.បង្គាប់ឲ្យកូនបំណុល ទាំងអ្នកស្រី និងអ្នកធានាបំណុលរួមគ្នាសងប្រាក់ដើមចំនួនដប់ពីរលាន រៀល និង ប្រាក់ការព្រាត់ថ្លៃ ទៅឲ្យដើមចោទ ដោយហេតុថា ក៏ហួសពេលកំណត់នៅក្នុងកិច្ចសន្យាខ្ចីនេះ គឺកូនបំណុល និងអ្នកធានា ជាអ្នកបង្ករឿងទាំងអស់។ ការខូចខាតរបស់ដើមចោទដែលបង្ករឿងដោយកូនបំណុល គឺមាន ជាក់ស្តែង និងក្រៅពីកូនបំណុលសងសំណង ខូចខាតនេះប្រាប់ដល់ដើមចោទ ដោយមិនចាំបាច់ចាំសាលក្រម ក្លាយជាស្ថាពរឡើយ។

គ.សុំឲ្យប្រកាសសាលក្រមនេះ មានអានុភាពអនុវត្តជាបណ្តោះអាសន្ន ដោយហេតុថា រឿងក្តីនេះ គឺជាការទាមទារប្រាក់ ជារឿងក្តីដែលទាក់ទងនឹងសិទ្ធិលើទ្រព្យសម្បត្តិ ដែលតាមមាត្រា១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺតុលាការអាចប្រកាសសាលក្រមនេះមានអនុវត្តជាបណ្តោះអាសន្នបាន ដោយការធានា ឬគ្មានការធានា ដើម្បីការពារផលប្រយោជន៍ដើមចោទ មិនឲ្យមានការខាតបង់ជាបន្តទៀត។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **លោកប្រធាន** មេត្តាសម្រេចតាមសំណូមពររបស់ខ្ញុំ ដូចមានចែងក្នុងកម្មវត្ថុខាងលើ ដោយសេចក្តីអនុគ្រោះ។

សូម **លោកប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃ ខែ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២,

ត្រូវនឹង ថ្ងៃទី ខែ ឆ្នាំ២០១៩

**ស្នាមម្រាមដៃ និងឈ្មោះ**



**លោកស្រី សៀង ម៉ីលី**

*សូមភ្ជាប់ជូន មកជាមួយនូវឯកសារភស្តុតាង ដូចជា:*

១. កិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៨

២. លិខិតបញ្ជាក់ទទួលប្រាក់ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៨

៣. លិខិតធានាដោយតម្កល់បណ្ណ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៨

៤. លិខិតជូនដំណឹង ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨

បានឃើញស្នាមមេដៃស្តាំ

ឈ្មោះ សៀង ម៉ីលី ផ្តិតចំពោះមុខមេធាវីពិតប្រាកដមែន។

**ហត្ថលេខា និងឈ្មោះមេធាវី**

ហេង ប៊ុន សេរីញ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យបណ្តឹង

**ដើមបណ្តឹង** : លោកស្រី .................. អាយុ ........... ឆ្នាំ ជនជាតិ ..............មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ: .............. ភូមិ .............. សង្កាត់ .................រាជធានី ......................។

**ចុងចម្លើយ** : លោក ...................... អាយុ ........... ឆ្នាំ ជនជាតិ ............និងលោកស្រី .............. ................. អាយុ......... ឆ្នាំ ........មានទីលំនៅបច្ចុប្បន្នផ្ទះលេខ : .............. ភូមិ...... ................ សង្កាត់ .................. ខណ្ឌ ................ រាជធានីភ្នំពេញ .................... ..................... ជាសហចុងចម្លើយ ។

## សូមគោរពចូលមក

.......................................................

### I. សាលក្រមដែលដើមបណ្តឹងទាមទារ:

១- បង្គាប់អោយឈ្មោះ ..................... និងឈ្មោះ ................ សហចុងចម្លើយសងប្រាក់ចំនួន ........................ USD (.................. ដុល្លារអាមេរិក) តាមកិច្ចសន្យាខ្ចីចងការប្រាក់ មកអោយនាងខ្ញុំ ។

២- បង្គាប់អោយឈ្មោះ ..................... និងឈ្មោះ ......................សហចុងចម្លើយសងប្រាក់ចំនួន ................ USD (.................. ដុល្លារអាមេរិក) ដែលនាងខ្ញុំលក់ផ្ទះរបស់នាងខ្ញុំយកប្រាក់ទៅសងជូសឈ្មោះ .........................និងឈ្មោះ ......................... ខ្ចីគេមកអោយនាងខ្ញុំ ។

៣-បង្គាប់អោយឈ្មោះ ............................ និងឈ្មោះ.....................ផ្តល់ថ្លៃខាតពេលវេលាសំណងជម្ងឺចិត្ត សេវាមេធាវី និងចំណាយផ្សេងៗ ចំនួន ............. USD (.............**ដុល្លារអាមេរិក**)។

៤-សុំអោយតុលាការចេញសាលក្រមមានអានុភាពអនុវត្តជាបណ្តោះអាសន្ន ។

៥-ប្រាក់ពន្ធលើកម្មវត្ថុបណ្តឹង និងប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ។

### II. អង្គហេតុចាំបាច់បញ្ជាក់ពីការទាមទាររបស់ដើមបណ្តឹង

ឈ្មោះ .................. ជាកូនចិញ្ចឹមរបស់នាងខ្ញុំ ដែលនាងខ្ញុំបានទទួលយកមកចិញ្ចឹមតាំងតែពីតូចមកម្ល៉េះ នាងខ្ញុំមានការអាណិត ស្រលាញ់ និងបានផ្គត់ផ្គង់ ទំនុកបំរុង ឈ្មោះនេះអោយបានរៀនសូត្រមានចំណេះដឹងខ្ពង់ខ្ពស់ និងបានជួយជ្រុមជ្រែងអោយបានការងារល្អធ្វើ ដោយពុំបានគិតពីការនឿយហត់ លំបាកម្តងណាឡើយ ។

នៅឆ្នាំ .......... នាងខ្ញុំបានទិញដីទំហំ ................. ស្ថិតនៅភូមិ ................ សង្កាត់ .................. ខណ្ឌ.............. រាជធានីភ្នំពេញ .............. ក្នុងតម្លៃ ............ USD (............**ដុល្លាអាមេរិក**) ក្នុងមួយម៉ែត្រការ៉េ សរុបចំនួន........... USD (**ដុល្លារអាមេរិក**) នៅក្នុងដំណាក់កាលនៃការផ្ទេរសិទ្ធិដីនេះ កូនចិញ្ចឹមរបស់នាងខ្ញុំ ឈ្មោះ ...................... និងប្រពន្ធឈ្មោះ .............. បានលួងលោមនាងខ្ញុំអោយដាក់ឈ្មោះរបស់ពួកគេលើដីនោះ ដោយធានាមើលថែរក្សានាងខ្ញុំរហូតដល់ចាស់ស្លាប់ ពេលឮពាក្យធានាមើលថែរក្សាដូចនេះ នាងខ្ញុំបានសម្រេចចិត្តផ្ទេរដាក់ ឈ្មោះ............... និងប្រពន្ធឈ្មោះ ............... ក្នុងវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលវត្ថុលេខ: ....................... ចុះថ្ងៃទី................ របស់មន្ទីរសុរិយោដីដែលនាងខ្ញុំបានទិញនេះ ហើយឯកសារច្បាប់ដើម គឺ រក្សានៅជាមួយនាងខ្ញុំ ។ នៅក្នុងខណៈនោះឈ្មោះ .................. និងប្រពន្ធឈ្មោះ ................ បានខ្ចីប្រាក់គេ (យាយសឡា) ចំនួន .................. USD (............**ដុល្លាអាមេរិក**) យកមកសាងសង់ផ្ទះ ពេលនោះអ្នកទាំងពីរនេះ ពុំអាចរកប្រាក់បង់ការប្រាក់និងសងប្រាក់ដើមអោយម្ចាស់ប្រាក់បានទេ ក្នុងនាមជាម្តាយ នាងខ្ញុំបានលក់ផ្ទះលេខ: .............. ផ្លូវលេខ: ........... ភូមិ ............ សង្កាត់ ............រាជធានី.......។ ដែលជារបស់នាងខ្ញុំផ្ទាល់បានចំនួន ................USD (................. ដុល្លារអាមេរិក) ។ ការលក់ផ្ទះនេះ គឺនាងខ្ញុំពុំមានសល់ប្រាក់មួយសេនទេ ព្រោះយកទៅសងថ្លៃ ឈ្មោះ ...................... និងឈ្មោះ ............... ជំពាក់គេទាំងអស់ ។

នៅឆ្នាំ ............ ឈ្មោះ ............. និងឈ្មោះ ................ បានបង្កើតកិច្ចសន្យាខ្ចីចងការប្រាក់ចុះថ្ងៃទី ......................... ជាមួយនាងខ្ញុំ ដើម្បីអោយនាងខ្ញុំកាន់តែមានភាពជឿជាក់ក្នុងការមើលថែរក្សាពីពួកគេ និងដើម្បីពួកគេបាន យកឯកសារប្លង់ដីច្បាប់ដើមពីនាងខ្ញុំទៅដាក់បញ្ចាំខ្ចីប្រាក់គេចំនួន .......... USD (................. ដុល្លារអាមេរិក) ក្នុងកិច្ចសន្យាខ្ចីចង់ការប្រាក់នេះ ដោយចាត់ទុកនាងខ្ញុំជាម្ចាស់ប្រាក់ និង ពួកគេជាកូនបំណុល ចំនួន ...................USD (...................... ដុល្លារអាមេរិក) ។

**លោកប្រធាន** ជាទីគោរព ! ស្រាប់តែចាប់ពីក្រោយធ្វើកិច្ចសន្យាខ្ចីចងការប្រាក់នេះ និងបានដឹងថានាងខ្ញុំមានជម្ងឺមហារីក និងពួកគេបានឯកសារប្លង់ដីច្បាប់ដើមពីនាងខ្ញុំផង ស្រាប់តែឈ្មោះ ...................... និងប្រពន្ធឈ្មោះ ...............ពុំបានបំពេញកាតព្វកិច្ចមើលថែរក្សានាងខ្ញុំទេ ថែមទាំងមិនអោយនាងខ្ញុំចូលស្នាក់នៅក្នុងផ្ទះលើដីដែលជារបស់នាងខ្ញុំទៀតមិនតែប៉ុណ្ណោះ ប្រាក់ដែលត្រូវជួយចិញ្ចឹមនាងខ្ញុំ ក៏ពួកគេមិនបានផ្តល់អោយនាងខ្ញុំដែរ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើសូម **លោកប្រធាន** មេត្តាចេញសាលក្រមតាមការទាមទាររបស់នាងខ្ញុំ ដោយក្តីអនុគ្រោះ ។

សូម **លោកប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ ពីនាងខ្ញុំ ។

ធ្វើនៅថ្ងៃទី ........ ខែ.....ឆ្នាំ........

**ស្នាមមេដៃស្តាំ**

**ឯកសារជូនភ្ជាប់មកជាមួយ**

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ
លេខ: .............. ចុះថ្ងៃទី ........................។

-កិច្ចសន្យាខ្ចីចងការប្រាក់ ចុះថ្ងៃទី ........................។

-កិច្ចសន្យាលក់ដី និងទទួលប្រាក់កក់ ចុះថ្ងៃទី ................................។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

---

ក្រុមមេធាវី យុត្តិធម៌ និងសច្ចៈធម៌
លេខ:........................

## ពាក្យសុំពិនិត្យ និងថតចម្លងសំណុំរឿង

ខ្ញុំបាទមេធាវី សុខ ចំរើនជាតិ អត្តលេខ: ២២២ ការិយាល័យ: ក្រុមមេធាវី យុត្តិធម៌ និងសច្ចៈធម៌ មានអាសយដ្ឋាននៅផ្ទះលេខ: ១៥ មហាវិថីម៉ៅសេទុង សង្កាត់ទួលស្វាយព្រៃ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**សូមគោរពជូន**
**លោកប្រធាន សាលាដំបូងខេត្ត-រាជធានីភ្នំពេញ**

**កម្មវត្ថុ** : សំណើសុំពិនិត្យ និងថតចម្លងសំណុំរឿង នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ: ១៤ ស.រ ចុះថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ។
**យោង** : មាត្រា ២៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមការអនុញ្ញាតពី លោកប្រធាន ដើម្បីធ្វើការពិនិត្យ និងថតសំណុំរឿងដូចបានជម្រាបជូនខាងលើ ដើម្បីឲ្យខ្ញុំបាទមានលទ្ធភាពសិក្សាស្រាវជ្រាវ ការពារផលប្រយោជន៍ស្របច្បាប់ឲ្យកូនក្តីខ្ញុំបាទ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោកប្រធាន មេត្តាសម្រេចអនុញ្ញាតតាមការស្នើសុំ ដោយក្តីអនុគ្រោះ។

សូម លោកប្រធាន ទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី....ខែ.........ឆ្នាំ ២០១៧
**ស្នាមមេដៃស្តាំ**

បានឃើញ និងយល់ព្រម
រាជធានីភ្នំពេញ ថ្ងៃទី....ខែ.........ឆ្នាំ ២០១៧
**ហត្ថលេខា និងត្រា**

បានឃើញ និងយល់ព្រម
រាជធានីភ្នំពេញ ថ្ងៃទី....ខែ.........ឆ្នាំ ២០១៧
**គ្រូកម្មសិក្សា**